# សាលាភូមិន្ទរដ្ឋបាល
# កំណែទម្រង់រដ្ឋបាល

## ខែមករា ឆ្នាំ២០១៨


**ឧទ្ទេសនាមដោយៈ ឈួន ឆាម**

**ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី**

chhuon.chham@gmail.com

012 923 556

# មាតិកា

ក. និយមន័យ រដ្ឋបាលសាធារណៈ

ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

គ. ការវិវត្តនៃរដ្ឋបាលសាធារណៈកម្ពុជាក្រោយឆ្នាំ១៩៧៩

ឃ. សមិទ្ធផលសម្រេចបាន

ង. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

# ក. និយមន័យរដ្ឋបាលសាធារណៈ

**វចនានុក្រមសម្តេចសង្ឃ ជួន ណាត**

រដ្ឋបាលៈ អ្នករក្សាដែន ឬ ប្រទេស; ក្រសួងរាជការកាន់កាប់

កិច្ចការក្នុងប្រទេស

# ក. និយមន័យរដ្ឋបាលសាធារណៈ

និយមន័យមុខងារ( Definition fonctionnelle ):

- ជាសំណុំសកម្មភាពទាំងឡាយ ធ្វើឡើងក្នុងគោលបំណង បំពេញសេចក្តីត្រូវការរបស់សមូហភាព ឆ្លើយតបទៅនឹង ផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ( ឧ. សណ្តាប់ធ្នាប់សាធារណៈ, ការផ្តល់សេវាសាធារណៈ... )

# ក. និយមន័យរដ្ឋបាលសាធារណៈ

និយមន័យអង្គការ( Definition organique ):

- ជាសំណុំនីតិបុគ្គល (ដូចជា រដ្ឋ, សមូហភាពដែនដី, គ្រឹស្ថានសាធារណៈ... ) និងរូបវន្តបុគ្គល (ដូចជា មន្ត្រីរាជការ, បុគ្គលិកជាប់កិច្ចសន្យា... ) ដែលមានតួនាទីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ

# ក. និយមន័យរដ្ឋបាលសាធារណៈ

ទស្សនវិទូ Raul P. de Guzment:

ទីណាមានរដ្ឋាភិបាល ទីនោះមានរដ្ឋបាលសាធារណៈ

មានន័យថា រដ្ឋបាលសាធារណៈ គឺជាកិច្ចសហប្រតិបត្តិ

ការរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ដើម្បីសម្រេចគោល

ដៅអ្វីមួយ ក្នុងការបម្រើប្រយោជន៍សាធារណៈ

# ក. និយមន័យរដ្ឋបាលសាធារណៈ

ទស្សនវិទូ Robert Presthus:

- រដ្ឋបាលសាធារណៈ គឺជាទិដ្ឋភាពនៃការគ្រប់គ្រង ដែលធ្វើឡើងដោយភ្នាក់ងារផ្លូវការគ្រប់លំដាប់ថ្នាក់របស់រដ្ឋាភិបាល
- រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលរបស់រដ្ឋ

# តួនាទីរបស់រដ្ឋបាលសាធារណៈ

រដ្ឋបាលសាធារណៈ អនុវត្តតួនាទី និងមុខងារជាច្រើន

តែមុខងារចម្បងៗមាន៖

- អនុវត្តច្បាប់(ជាកាតព្វកិច្ច)
- រក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ស្ថិរភាព
- គ្រប់គ្រងផ្ទាល់សេវាសាធារណៈ

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

- រដ្ឋបាលមុនអាណានិគមបារាំង
- រដ្ឋបាលក្រោមអាណាព្យាបាលរបស់បារាំង
- រដ្ឋបាលសាធារណៈ ក្រោយអាណាព្យាបាលរបស់បារាំង

(សម័យសង្គមរាស្ត្រនិយម  សាធារណរដ្ឋខ្មែរ កម្ពុជាប្រជាធិបតេយ្យ)

- រដ្ឋបាលសាធារណៈបច្ចុប្បន្ន (ក្រោយថ្ងៃ៧ មករា ១៩៧៩)

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

➢ **រដ្ឋបាលមុនសម័យអាណានិគមបារាំង**

- ជារបបរាជានិយម
- អំណាចនយោបាយ និងអំណាចរដ្ឋបាល ស្ថិតនៅក្រោមព្រះមហាក្សត្រ
- ច្បាប់យកចេញពីគម្ពីរវេទ និងទំនៀមទម្លាប់មកប្រតិបត្តិ
- ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យបញ្ញាតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះតែប៉ុណ្ណោះ

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

➢ **រដ្ឋបាលមុនអាណានិគមបារាំង(ត)**

- ក្នុងសម័យយុគកណ្តាល ព្រះមហាក្សត្រទ្រង់ធ្វើសវនាការកិច្ចការរដ្ឋបាល ២ដង ក្នុងមួយថ្ងៃ(កំណត់ហេតុជីវតាក្វាន់ ១២៩៦)
- ព្រះមហាក្សត្រទ្រង់ដឹកនាំចម្បាំងដោយផ្ទាល់(ទ្រង់ជាមេបញ្ជាការកំពូល)
- ទ្រង់ជាអធិបតីនៃសេនាបតីសភា(ការប្រជុំគណៈរដ្ឋមន្ត្រី)

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

- សេនាបតី:

- សេនាបតី ឧកញ៉ា ឬសម្ដេចចៅហ៊្វា.........នាយករដ្ឋមន្ត្រី
- សេនាបតី ឧកញ៉ាយោមរាជ.........រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- សេនាបតី ឧកញ៉ាវាំង.........រដ្ឋមន្ត្រីព្រះបរមរាជវាំង និងហិរញ្ញវត្ថុ
- សេនាបតី ឧកញ៉ា ឬសម្ដេចចក្រី.........រដ្ឋមន្ត្រីខាងដឹកជញ្ជូនតាមជើងគោក និងខាងកងទ័ព
- សេនាបតី ឧកញ៉ាក្រឡាហោម.........រដ្ឋមន្ត្រីខាងដឹកជញ្ជូនតាមជើងទឹក

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

## ➢ រដ្ឋបាលក្រោមអាណាព្យាបាលរបស់បារាំង

- សន្ធិសញ្ញាឆ្នាំ១៨៦៣ ដាក់ប្រទេសកម្ពុជាឱ្យស្ថិតនៅក្រោមអាណាព្យាបាលរបស់ប្រទេសបារាំង
- បារាំងដកអំណាចពិតប្រាកដទាំងអស់ចេញពីមហាក្សត្រខ្មែរផ្ទេរទៅឱ្យលោក Résident supérieur
- កិច្ចប្រជុំសេនាបតីសភា ត្រូវស្ថិតនៅក្រោមអធិបតីលោក Résident supérieur

# ខ. ប្រវត្តិរដ្ឋបាលសាធារណៈកម្ពុជា

➢ **រដ្ឋបាលសាធារណៈ ក្រោយអាណាព្យាបាលរបស់បារាំង**

- សម័យសង្គមរាស្ត្រនិយម
- របបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់
- របបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត

# គ. រដ្ឋបាលសាធារណៈកម្ពុជា ក្រោយថ្ងៃ៧ មករា ១៩៧៩

- ➢ ១៩៧៩-១៩៩៣៖ ការកកើតរដ្ឋបាលឡើងវិញ
- ➢ ១៩៩៣-១៩៩៨ ៖ ការបង្រួបបង្រួមនិងផ្សះផ្សាជាតិ
- ➢ ១៩៩៨-២០០៣ ៖ ការពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ
- ➢ ២០០៣-២០០៨៖ ការកែទម្រង់ស៊ីជម្រៅ
- ➢ ២០០៨-២០១៣៖ ការបន្តធ្វើកំណែទម្រង់ស៊ីជម្រៅ



# ឃ. សមិទ្ធផលសម្រេចបាន

- បង្កើតគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងដើម្បីកែទម្រង់រដ្ឋបាល
- កសាងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា( សភាអនុម័ត ២១ តុលា ១៩៩៤ )
- យុទ្ធនាការរាប់មន្ត្រីរាជការស៊ីវិលទូទាំងប្រទេស( ៧ កុម្ភៈ ១៩៩៥ )
- អនុក្រឹត្យស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ( តុលា១៩៩៥ )
- សមាហរណកម្មភាគីនយោបាយនិងនិស្សិតប្រមាណ ២៥000នាក់ចូលក្នុងរដ្ឋបាលជាតិ ( ១៩៩៥-១៩៩៨ )
- សមាហរណកម្មភាគីខ្មែរក្រហម ( ១៩៩៨-១៩៩៩ )

## ឃ. សមិទ្ធផលសម្រេចបាន(ត)

- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន(មេសា ១៩៩៦)
- ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ (ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧)
- យុទ្ធនាការជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស(១៩៩៩-២០០១)
- បង្កើតមូលដ្ឋានទិន្នន័យព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- កសាងលក្ខន្តិកៈដោយឡែកតាមប្រភេទក្របខ័ណ្ឌចំនួន ២១

## ឃ. សមិទ្ធផលសម្រេចបាន (ត)

- កសាងបទដ្ឋានគតិយុត្តជាច្រើនទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- រៀបចំយុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈ
- បង្កើត និង ដាក់ឱ្យអនុវត្តប្រព័ន្ធចំណាត់ថ្នាក់ថ្មី **ក ខ គ ឃ**
- ធ្វើសមាហរណកម្មមន្ត្រីរាជការពីប្រព័ន្ធចាស់ទៅប្រព័ន្ធចំណាត់ថ្នាក់ថ្មី
- បង្កើត និង ដាក់ឱ្យអនុវត្តប្រព័ន្ធលាភការថ្មី
- បង្កើត និង ដាក់ឱ្យដំណើរការតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា

# ឃ. សមិទ្ធផលសម្រេចបាន(ត)

- ដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំឆ្នាំជូនមន្ត្រីរាជការស៊ីវិល តាមគោល
  នយោបាយរបស់រាជរដ្ឋាភិបាល
- កសាងគោលនយោបាយស្តីពី ការផ្តល់សេវាសាធារណៈ
- កែសម្រួលគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បង្កើតឱ្យមានបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ

## ខ. កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល

- ចក្ខុវិស័យ
- គោលបំណង
- គោលដៅ
- យុទ្ធសាស្រ្ត
- ផែនការសកម្មភាព

## ចក្ខុវិស័យ៖

"បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង"

## គោលបំណង៖

"ប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវា
ដ៏ស័ក្តិសិទ្ធិ"

## គោលដៅ៖

១-ធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានភាពឆ្លើយតប

ជំនឿទុកចិត្ត ប្រសិទ្ធភាព និងប្រសិទ្ធផល

២-លើកកម្ពស់គុណសម្បត្តិនៃវប្បធម៌សេវាសាធារណៈ

ឆន្ទៈម្ចាស់ការ ភក្តីភាព និង មនសិការវិជ្ជាជីវៈ

## យុទ្ធសាស្ត្រ៖

១- ពង្រឹងគុណភាព និង ប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ

២- អភិវឌ្ឍសមត្ថភាព

៣- កែលំអការងារគ្រប់គ្រង

៤- កែលំអប្រព័ន្ធលាភការ

៥- ពង្រឹងការគ្រប់គ្រងក្របខ័ណ្ឌ និងការពង្រាយមន្ត្រីរាជការស៊ីវិល

## ផែនការសកម្មភាព៖

១- ឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ

២- គោលនយោបាយធនធានមនុស្ស(គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស)

៣- ការពិនិត្យមើលប្រតិបត្តិការរបស់ក្រសួងស្ថាប័ន

៤- គោលការណ៍កំណែទម្រង់បៀវត្ស

៥- ព្រះរាជក្រឹត្យប្រឡងចូលក្របខ័ណ្ឌ ផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌ...រៀបចំគោលការណ៍ពង្រាយមន្ត្រីរាជការ

# បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង



# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល

«បម្រើ
ប្រជាជន
ឱ្យបានកាន់តែ
ល្អប្រសើរឡើង »







១-គុណភាពព័ត៌មាន

២-ភាពងាយស្រួលក្នុងការទទួលយកសេវា

៣-ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា

៤-សេវាផ្តល់តាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ

៥-យន្តការព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល




«បម្រើ

ប្រជាជន

ឱ្យបានកាន់តែ

ល្អប្រសើរឡើង »




១-កែលម្អរបៀបរបបគ្រប់គ្រងការចាត់ចែងការងារ

២-ពង្រឹងការគ្រប់គ្រងជំនាញនិងចំនួនមន្ត្រី (Personnel management) តាមតម្រូវការ

៣-លើកកម្ពស់គុណផល (Performance) និងការទទួលខុសត្រូវរបស់មន្ត្រី

៤-អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រី

៥-ពង្រឹងសីលធម៌និងវិន័យ

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល

**«បម្រើ**
**ប្រជាជន**
**ឱ្យបានកាន់តែ**
**ល្អប្រសើរឡើង »**




១- ធានាប្រសិទ្ធភាព និងមានផលប៉ះពាល់ជាវិជ្ជមាន ដល់ការផ្តល់សេវាសាធារណៈ

២- គ្រប់មុខតំណែងក្នុងវិស័យសាធារណៈមានបៀវត្សរ៍មូលដ្ឋាន

៣- ប្រាក់បំណាច់មុខងារមិនលើសពី បៀវត្សរ៍មូលដ្ឋាន

៤-កាត់បន្ថយគម្លាតបៀវត្សរ៍ ដោយបង្កើនបៀវត្សរ៍ទាបឱ្យបានលឿនជាងបៀវត្សរ៍ខ្ពស់

៥- រក្សាសមធម៌និងសង្គតិភាពរវាងក្របខ័ណ្ឌស៊ីវិល និង ក្របខ័ណ្ឌកងកម្លាំងប្រដាប់អាវុធ

៦- រក្សាស្ថិរភាពនិងចីរភាពហិរញ្ញវត្ថុសាធារណៈនិងម៉ាក្រូសេដ្ឋកិច្ច



# គុណភាពធនធានមនុស្ស

- ប្រព័ន្ធចំណាត់ថ្នាក់
- ការរៀបចំក្របខ័ណ្ឌ
- គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ
- គោលនយោបាយធនធានមនុស្ស
- ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល
- ការពិនិត្យប្រតិបត្តិការឡើងវិញ

# ប្រព័ន្ធមុខងារសាធារណៈ

**ប្រព័ន្ធអាជីព** ( Career System ) គឺជាគោលការណ៍គ្រប់គ្រងមន្ត្រីរាជការ ដោយផ្អែកលើលក្ខខណ្ឌសំខាន់ៗមួយចំនួនដូចជា ការជ្រើសរើសចូលក្របខ័ណ្ឌមុខងារសាធារណៈ ការបណ្តុះបណ្តាល និងការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ (មានប្រភេទឋានន្តរស័ក្តិ និងថ្នាក់) ការវិវត្ត និងការផ្លាស់ប្តូរក្របខ័ណ្ឌ អតីតភាព និង ការចូលនិវត្តន៍នៅដំណាក់កាលចុងក្រោយ និង តារាងសន្ទស្សន៍បៀវត្សជាដើម។

# ប្រព័ន្ធមុខងារសាធារណៈ

**ប្រព័ន្ធនិយោជន៍** (Employment System) គឺជាប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដោយផ្អែកលើបទពិសោធន៍ការងារ សមត្ថភាពការងារ ចំណេះដឹងចំណេះធ្វើ និងគុណសម្បត្តិបុគ្គល លក្ខខណ្ឌ និងការងារដែលបានប្រគល់ជូន (Task Assignment) ក្នុងរយៈពេលកំណត់ពោលគឺជារបៀបគ្រប់គ្រងតាមគោលដៅ (Management by Objectives) និងតាមការងារអាទិភាព។

# ប្រព័ន្ធចំណាត់ថ្នាក់

**ចំណាត់ថ្នាក់**មន្ត្រីរាជការ គឺជាប្រតិបត្តិការបច្ចេកទេសមួយដ៏ចាំបាច់សម្រាប់ការគ្រប់គ្រងមុខងារសាធារណៈ និងរៀបចំមុខងារសាធារណៈឱ្យមានរចនាសម្ព័ន្ធផ្ទាល់មួយសម្រាប់ជាមូលដ្ឋានក្នុងប្រតិបត្តិការនៃការជ្រើសរើស  ការគ្រប់គ្រងអាជីព និងការដាក់ឱ្យដំណើរការប្រព័ន្ធលាភការមួយសមស្រប។

# ប្រព័ន្ធចំណាត់ថ្នាក់បច្ចុប្បន្ន

| ប្រភេទ ក្របខ័ណ្ឌ | លក្ខខណ្ឌចូលក្របខ័ណ្ឌ | មុខងារ |
|---|---|---|
| **ក** | ចាប់ពីបរិញ្ញាប័ត្រឡើង | មុខងារដឹកនាំ អធិការកិច្ច សិក្សា ផ្តល់យោបល់ក្នុងអង្គភាពក្នុងអង្គភាពរដ្ឋបាល គតិយុត្ត សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស សង្គមកិច្ច |
| **ខ** | បាក់ឌុប បូក ២ឆ្នាំ | ជំនួយការងារដល់ **ក** និង បំពេញមុខតំណែងដឹកនាំកម្រិតមធ្យម |
| **គ** | បាក់ឌុប | លេខាធិការ មុខងារផ្នែករដ្ឋបាល និងត្រួតពិនិត្យការងាររបស់ភ្នាក់ងារ **ឃ** |
| **ឃ** | មិនតម្រូវសញ្ញាប័ត្រ | កិច្ចការប្រតិបត្តិនៅក្នុងអង្គភាព |

**ការបែងចែកក្របខ័ណ្ឌ:** ក្របខ័ណ្ឌ **ក ខ គ** ត្រូវបានបែងចែកជា ៣ ឋានន្តរស័ក្តិ

- ឋានន្តរស័ក្តិទី១ មាន ០៦ថ្នាក់ (បន្ទាប់ពី ៤ថ្នាក់នៅឋានន្តរស័ក្តិទី ៣ និង ៤ថ្នាក់នៅឋានន្តរស័ក្តិទី ២)
- ឋានន្តរស័ក្តិទី២ មាន ១០ថ្នាក់ (បន្ទាប់ពី ៤ ថ្នាក់នៅឋានន្តរស័ក្តិទី ៣)
- ឋានន្តរស័ក្តិទី៣ មាន ១៤ថ្នាក់ (១២ ខែ បន្ទាប់ពីកម្មសិក្សាដោយជោគជ័យ)

ក្របខ័ណ្ឌ **ឃ** មានតែ **១** ឋានន្តរស័ក្តិប៉ុណ្ណោះ

# អំពីក្របខ័ណ្ឌ

•ក្របខ័ណ្ឌនីមួយៗនៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារដែលមានគុណសម្បត្តិ ឬការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬប្រភេទមុខតំណែងដូចគ្នាក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ។

• ក្របខ័ណ្ឌនីមួយៗត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយដែលរៀបចំដោយក្រសួងសាមីនិងក្រសួងមុខងារសាធារណៈ។

# អំពីក្រាបខ័ណ្ឌ

- **លក្ខន្តិកៈដោយឡែក ត្រូវមានជាចាំបាច់នូវបទប្បញ្ញត្តិដូចតទៅ៖**

ក- ការភ្ជាប់ក្រាបខ័ណ្ឌក្នុងក្រសួងមួយ

ខ- ការចាត់ថ្នាក់ក្រាបខ័ណ្ឌទៅក្នុងប្រភេទមួយ

គ- ការកំណត់បេសកកម្មទូទៅរបស់ក្រាបខ័ណ្ឌ

ឃ- ការកំណត់មុខតំណែង ដែលភ្នាក់ងារក្រាបខ័ណ្ឌត្រូវបំពេញ

# អំពីក្របខ័ណ្ឌ

ង- ការកំណត់លក្ខណៈសម្បត្តិអប្បបរមាដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និងបែបបទនៃការប្រឡងប្រជែងផ្ទៃក្នុង និងការប្រឡងប្រជែងចូលក្របខ័ណ្ឌរាជការ ដោយនិស្សិតសុទ្ធសាធ

ច- របបកម្មសិក្សាសាកល្បង

ឆ- ការកំណត់ឋានានុក្រមក្របខ័ណ្ឌ (បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និងកំណត់មុខតំណែងសម្រាប់ឋានន្តរស័ក្តិនីមួយៗ)

ជ- វិធានសម្រាប់ដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ។

# អំពីប្រភេទ

•ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ ប្រភេទ **ក ខ គ** និង **ឃ** ដែលកំណត់ឡើងដោយយោងទៅតាមលក្ខខណ្ឌអប្បបរមានៃការបណ្តុះបណ្តាល សម្រាប់បញ្ចូលក្នុងក្របខ័ណ្ឌ និងកម្រិតឋានានុក្រមនៃតំណែងរបស់ក្របខ័ណ្ឌ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃប្រភេទទាំង ៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន។

# អំពីឋានន្តរសក្តិ

- ឋានន្តរស័ក្តិ គឺជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ។ ក្របខ័ណ្ឌនីមួយៗចាំបាច់ត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិឋានានុក្រម។ ឋានន្តរស័ក្តិនីមួយៗ ឆ្លើយតបទៅនឹងមុខតំណែង ឬសារព័ន្ធមុខតំណែងដែលមានការទទួលខុសត្រូវកាន់តែខ្ពស់។
- និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងឱ្យចូលក្នុងមុខងារសាធារណៈ ចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ។

# អំពីថ្នាក់

- ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ ដែលមានសន្ទស្សន៍កំណត់អំពីកម្រិតលាភការ ។
- ឋានន្តរស័ក្តិ ទី ១ ត្រូវបានចែកចេញជា ១៤ ។ ឋានន្តរស័ក្តិ ទី២ ចែកចេញជា ១០ថ្នាក់។ ឋានន្តរស័ក្តិ ទី ៣ចែកចេញជា ៦ថ្នាក់ ។
- ជាធម្មតា មន្ត្រីរាជការទាំងអស់ ត្រូវបានដំឡើងថ្នាក់ក្នុង ២ឆ្នាំម្តង វៀរលែងក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ ស្តីពីអតីតភាពដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬ ពីលក្ខណៈស្ថិតក្នុងតំបន់ដាច់ស្រយាលនៃមុខតំណែងខ្លះ។

# ក្របខណ្ឌ ក ៖ មន្ត្រីគ្រប់គ្រងរដ្ឋបាល & មន្ត្រីរដ្ឋបាលជាន់ខ្ពស់ម.ផ

| ប្រភេទ | ឋានន្តរស័ក្តិ | ឈ្មោះ | មុខងារ |
|---|---|---|---|
| ក | ១ | ឧត្តមមន្ត្រី | អគ្គលេខាធិការ, អគ្គនាយក, អគ្គាធិការ, អភិបាលរាជធានី ខេត្ត |
| | ២ | វរៈមន្ត្រី | អគ្គលេខាធិការរង, អគ្គនាយករង, អគ្គាធិការរង, ប្រធាននាយកដ្ឋាន, អធិការ, អភិបាលរងរាជធានី ខេត្ត |
| | ៣ | អនុមន្ត្រី | អនុប្រធាននាយកដ្ឋាន, អធិការរង, ប្រធានមន្ទីរជំនាញនៅរាជធានី ខេត្ត, អភិបាលក្រុង ស្រុក ខណ្ឌ |

# ក្របខ័ណ្ឌ ២ ៖ មន្ត្រីក្រមការ & មន្ត្រីក្រមការក្រសួងមហាផ្ទៃ

| ប្រភេទ | ឋានន្តរស័ក្តិ | ឈ្មោះ | មុខងារ |
|---|---|---|---|
| ២ | ១ | នាយក្រមការ | ប្រធានការិយាល័យថ្នាក់កណ្តាល,<br>អនុប្រធានមន្ទីររាជធានី ខេត្ត, អភិបាលរង<br>ក្រុង ស្រុក ខណ្ឌ |
| | ២ | ក្រមការដើមខ្សែ | អនុប្រធានការិយាល័យថ្នាក់កណ្តាល,<br>ប្រធានការិយាល័យរាជធានី ខេត្ត |
| | ៣ | ក្រមការ | អនុប្រធានការិយាល័យមន្ទីរ,<br>ប្រធានការិយាល័យស្រុក ខ័ណ្ឌ |

# ក្របខ័ណ្ឌ គ ៖ លេខាធិការរដ្ឋបាល& លេខាធិការរដ្ឋបាល ម.ផ

| ប្រភេទ | ឋានន្តរស័ក្តិ | ឈ្មោះ | មុខងារ |
|---|---|---|---|
| គ | ១ | នាយលេខាធិការរដ្ឋបាល | |
| | ២ | លេខាធិការរដ្ឋបាល<br>ដើមខ្សែ | |
| | ៣ | លេខាធិការរដ្ឋបាល | |

# ក្របខ័ណ្ឌ ឃ ៖ ន្ធាក់ខាររដ្ឋបាល &ន្ធាក់ខាររដ្ឋបាល ម.ផ

| ប្រភេទ | ឋានន្តរស័ក្តិ | ឈ្មោះ | មុខងារ |
|---|---|---|---|
| ឃ | | | បំពេញមុខតំណែងក្នុង<br>កិច្ចការប្រតិបត្តិក្នុងអង្គភាព<br>រដ្ឋបាលកណ្តាល រាជធានី ខេត្ត |

| ប្រភេទក្របខណ្ឌ | ឈ្មោះក្របខណ្ឌ | | | | | |
|---|---|---|---|---|---|---|
| | រដ្ឋបាលទូទៅ | មហាផ្ទៃ | ការទូត | អប់រំ | សុខាភិបាល | បច្ចេកទេស |
| ក | មន្ត្រីគ្រប់គ្រងរដ្ឋបាល | មន្ត្រីរដ្ឋបាលជាន់ខ្ពស់ | មន្ត្រីការទូតជាន់ខ្ពស់ | គ្រូបង្រៀនកម្រិតឧត្តម | មន្ត្រីសុខាភិបាលជាន់ខ្ពស់ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ |
| ខ | មន្ត្រីក្រមការ | មន្ត្រីក្រមការ | មន្ត្រីក្រមការការបរទេស | គ្រូបង្រៀនកម្រិតមូលដ្ឋាន | មន្ត្រីសុខាភិបាលមធ្យម | មន្ត្រីបច្ចេកទេសមធ្យម |
| គ | លេខាធិការរដ្ឋបាល | លេខាធិការរដ្ឋបាល<br>អនុរក្សពន្ធនាគារ | | គ្រូបង្រៀនកម្រិតបឋម | មន្ត្រីសុខាភិបាលបឋម | មន្ត្រីបច្ចេកទេសបឋម |
| ឃ | ភ្នាក់ងាររដ្ឋបាល | ភ្នាក់ងាររដ្ឋបាល | | | | ភ្នាក់ងារបច្ចេកទេស |

| ប្រភេទក្របខណ្ឌ | ឈ្មោះក្របខណ្ឌ | | | | | |
|---|---|---|---|---|---|---|
| | រដ្ឋបាលទូទៅ | មហាផ្ទៃ | ការទូត | អប់រំ | សុខាភិបាល | បច្ចេកទេស |
| ក | មន្ត្រីគ្រប់គ្រង រដ្ឋបាល | មន្ត្រីរដ្ឋបាល ជាន់ខ្ពស់ | មន្ត្រីការទូត ជាន់ខ្ពស់ | គ្រូបង្រៀន កម្រិតឧត្តម | មន្ត្រីសុខាភិបាល ជាន់ខ្ពស់ | មន្ត្រីបច្ចេកទេស ជាន់ខ្ពស់ |
| ខ | មន្ត្រីក្រមការ | មន្ត្រីក្រមការ | មន្ត្រីក្រមការ ការបរទេស | គ្រូបង្រៀន កម្រឹតមូលដ្ឋាន | មន្ត្រីសុខាភិបាល មធ្យម | មន្ត្រីបច្ចេកទេស មធ្យម |
| គ | លេខាធិការ រដ្ឋបាល | លេខាធិការ រដ្ឋបាល<br>អនុរក្ស ពន្ធនាគារ | | គ្រូបង្រៀន កម្រិតបឋម | មន្ត្រីសុខាភិបាល បឋម | មន្ត្រីបច្ចេកទេស បឋម |
| ឃ | ភ្នាក់ងារ រដ្ឋបាល | ភ្នាក់ងារ រដ្ឋបាល | | | | ភ្នាក់ងារ បច្ចេកទេស |

# ក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

| ក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ<br>នស/រកត/០៨១៣/៨៩២( 07/08/13 ) | | |
|---|---|---|
| ឧត្តមអគ្គានុរក្ស ពន្ធនាគារ | ឋានន្តរសក្តិឧត្តមអគ្គានុរក្ស ពន្ធនាគារ មាន ៣ថ្នាក់ | ឧត្តមអគ្គានុរក្សថ្នាក់លេខ១ |
| | | ឧត្តមអគ្គានុរក្សថ្នាក់លេខ២ |
| | | ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ |
| វរអគ្គានុរក្ស ពន្ធនាគារ | ឋានន្តរសក្តិវរអគ្គានុរក្ស ពន្ធនាគារមាន ៣ថ្នាក់ | វរអគ្គានុរក្សថ្នាក់លេខ១ |
| | | វរអគ្គានុរក្សថ្នាក់លេខ២ |
| | | វរអគ្គានុរក្សថ្នាក់លេខ៣ |
| អគ្គានុរក្ស ពន្ធនាគារ | ឋានន្តរសក្តិអគ្គានុរក្ស ពន្ធនាគារមាន ៧ថ្នាក់ | អគ្គានុរក្សថ្នាក់លេខ១ |
| | | អគ្គានុរក្សថ្នាក់លេខ២ |
| | | អគ្គានុរក្សថ្នាក់លេខ៣ |
| | | អគ្គានុរក្សថ្នាក់លេខ៤ |
| | | អនុរក្សថ្នាក់លេខ១ |
| | | អនុរក្សថ្នាក់លេខ២ |
| | | អនុរក្សថ្នាក់លេខ៣ |

# ប្រព័ន្ធចំណាត់ថ្នាក់ - Classification System



# ប្រព័ន្ធចំណាត់ថ្នាក់បច្ចុប្បន្ន




មន្ត្រីរាជការម្នាក់ៗក្នុងឋានន្តរស័ក្តិទី៣ បំពេញការងារ ១៤ថ្នាក់ ឬ ២៨ឆ្នាំ

មន្ត្រីរាជការម្នាក់ៗក្នុងឋានន្តរស័ក្តិទី២ បំពេញការងារ ១៤ថ្នាក់ ឬ ២៨ឆ្នាំ (៨ + ២០)

មន្ត្រីរាជការម្នាក់ៗក្នុងឋានន្តរស័ក្តិទី១ បំពេញការងារ ១៤ថ្នាក់ ឬ ២៨ឆ្នាំ (៨ + ៨ + ១២)

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

១- វប្បធម៌សេវាសាធារណៈ

១.១- ការផ្លាស់ប្តូរឥរិយាបថ

១.២-អ្នកផ្តល់សេវា

១.៣- អ្នកប្រឹក្សាយោបល់

១.៤- ការសម្របសម្រួល

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

២- ឆន្ទៈម្ចាស់ការ (Motivation )

- ២.១- ទឹកចិត្តស្រឡាញ់ការងារ
- ២.២- ការមានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត
- ២.៣- ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម
- ២.៣- ការបំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុម
- ២.៥- ការជំនះឧបសគ្គ

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

៣-ភក្ដីភាព (Loyalty)

៣.១- ការយល់ដឹងអំពីសភាពការណ៍

៣.២-ភក្ដីភាពចំពោះស្ថាប័ន

៣.៣- ភក្ដីភាពចំពោះវិជ្ជាជីវៈ

៣.៤-ភក្ដីភាពចំពោះប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់សេវា

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ (Professionalism)

៤.១- មន្ត្រីរាជការត្រូវប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីបំពេញការងារជាមួយនឹងមធ្យោបាយដែលមាន

៤.២- មន្ត្រីរាជការត្រូវយកចិត្តទុកដាក់ឱ្យបានច្បាស់លាស់ក្នុងការបំពេញការងារ និងមានមនសិការ

៤.៣- មន្ត្រីរាជការ ត្រូវប្ដេជ្ញាចិត្តធ្វើការអភិវឌ្ឍខ្លួននិងប្រើប្រាស់សមត្ថភាព ចំណេះដឹង ជំនាញ ភាពប៉ិនប្រសប់ និង ចរិតលក្ខណៈរបស់ខ្លួនឱ្យបានជាអតិបរមា និង ប្រកបដោយសេចក្ដីថ្លៃថ្នូរ។

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

**៤- មនសិការវិជ្ជាជីវៈ**(Professionalism )

៤.៤- មន្ត្រីរាជការត្រូវស្ទិតស្វាញក្នុងការធ្វើការងារជាមួយមន្ត្រីរាជការដទៃទៀត និងត្រូវសម្រេចលទ្ធផលការងារជាមួយគ្នានោះ ឱ្យបានត្រឹមត្រូវ។

៤.៥- មន្ត្រីរាជការ ត្រូវហ៊ានលះបង់កម្លាំងកាយ និងចិត្តចំពោះការងារដែលមានជំនាញខ្ពស់ និងប្ដេជ្ញាចិត្ត បម្រើផលប្រយោជន៍សាធារណៈ។

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ(Professionalism )

៤.៦- មន្ត្រីរាជការ ចាំបាច់ត្រូវបង្កើនសមត្ថភាពជំនាញ ឯកទេស ចំណេះដឹង និងបទពិសោធន៍ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឱ្យទាន់សភាពការណ៍ជារៀងរហូត។

៤.៧- មន្ត្រីរាជការ មិនអាចយកពេលវេលាបំពេញការងារទៅប្រកបវិជ្ជាជីវៈឯកជនបន្ថែមដើម្បីយកកែម្រៃបានទេ ទោះជាក្នុងប្រភេទណាក៏ដោយគឺអាចធ្វើបានតែក្នុងករណីដែលច្បាប់អនុញ្ញាតប៉ុណ្ណោះ

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ(Professionalism )

៤.៨- មន្ត្រីរាជការមិនអាចទទួលយកដោយផ្ទាល់ ឬដោយប្រយោលតាមរយៈតំណាងរបស់ខ្លួន នូវផលប្រយោជន៍នានា ពីនរណាមួយ ឬពីសហគ្រាសមួយ

៤.៩- អ្នករាជការត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ (Secret professionnel ) តាមគោលការណ៍ និងស្មារតី ដូចមានចែងក្នុងច្បាប់ជាធរមាន

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ(Professionalism)

៤.១០-មន្ត្រីរាជការ ត្រូវប្រកាន់ខ្ជាប់នូវកាតព្វកិច្ចលក្ខណ៍ការណ៍មាន ន័យថា មិននិយាយ ឬសរសេរពីអ្វីដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និង កិត្យានុភាពរបស់អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន។

៤.១១-មន្ត្រីរាជការ ទោះជាស្ថិតក្នុងតួនាទី ឬឋានានុក្រមណាក៏ដោយ ត្រូវតែទទួលខុសត្រូវលើការប្រតិបត្តិរបស់ខ្លួន ចំពោះភារកិច្ចដែលបានប្រគល់ឱ្យ

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ(Professionalism )

៤.១២-មន្ត្រីរាជការ មានកាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួនទៅតាមការចាត់តាំងរបស់ថ្នាក់លើ ចៀសវាងការចន្លោះប្រហោងក្នុងការបំពេញមុខងារ របស់ខ្លួន ដែលនាំឱ្យមានការផ្គាំផ្គងនៅក្នុងវិជ្ជាជីវៈជាមន្ត្រីរាជការបម្រើរដ្ឋ។

៤.១៣- មន្ត្រីរាជការ មានកាតព្វកិច្ចគោរពវិន័យការងារម៉ោងពេលធ្វើការ និង បទបញ្ជាផ្ទៃក្នុងរបស់អង្គភាពឱ្យបានម៉ឺងម៉ាត់

# គុណភាពធនធានមនុស្ស

## គុណសម្បត្តិនៃឥរិយាបថមន្ត្រីរាជការ

### ៤- មនសិការវិជ្ជាជីវៈ(Professionalism )

៤.១៤-មន្ត្រីរាជការទាំងអស់ ត្រូវតែគោរពបទបញ្ជាថ្នាក់លើដែលបានចាត់ឱ្យទៅបម្រើការងារ ទោះជានៅទីណាក្តី

៤.១៥-រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលឋានានុក្រម តម្រូវឱ្យថ្នាក់ក្រោមគោរពថ្នាក់លើជាហូរហែតាមលំដាប់ថ្នាក់។ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវទៅតាមនីតិវិធី និងគោលការណ៍ គឺត្រូវគោរពឱ្យបាននូវគោលការណ៍នីតិរដ្ឋ។

# គោលនយោបាយធនធានមនុស្ស
# ក្នុងរដ្ឋបាលសាធារណៈ

១- ចក្ខុវិស័យ និងគោលបំណង

២- គោលដៅ

៣- វិសាលភាព

៤- យុទ្ធសាស្រ្ត

៥- ផែនការសកម្មភាព

៦- ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

# គោលនយោបាយធនធានមនុស្ស
# ក្នុងរដ្ឋបាលសាធារណៈ

## ១- ចក្ខុវិស័យ និងគោលបំណង

មន្ត្រីរាជការស៊ីវិលកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងការជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ តាមរយៈការធ្វើឱ្យមន្ត្រីរាជការស៊ីវិលប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ ហើយត្រូវបានចាត់ចែងឱ្យបំពេញការងារដោយផ្តោតលើតម្រូវការជាក់ស្តែង ប្រកបដោយប្រសិទ្ធផល និងសមធម៌។

# គោលនយោបាយធនធានមនុស្ស

## ២- គោលដៅ

២.១- កែលំអររបៀបរបបគ្រប់គ្រងការចាត់ចែងការងារ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីតួនាទី និងភារកិច្ច និងពីតម្រូវការធនធានមនុស្សទាំងបរិមាណនិងគុណភាព ដោយផ្អែកលើទំហំការងារ

២.២- ពង្រឹងការគ្រប់គ្រងជំនាញ និងចំនួនមន្ត្រីរាជការ តាមតម្រូវការ

២.៣- លើកកម្ពស់គុណផល និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ

២.៤- អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រីរាជការស៊ីវិល

២.៥- ពង្រឹងសីលធម៌ និង វិន័យមន្ត្រីរាជការស៊ីវិល

# គោលនយោបាយធនធានមនុស្ស

## ៣- វិសាលភាព

អនុវត្តចំពោះគ្រប់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

# គោលនយោបាយធនធានមនុស្ស

## ៤- យុទ្ធសាស្ត្រ

៤.១- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រប់គ្រង

៤.២- ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស

៤.៣- អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល

៤.៤- ប្រើប្រាស់ឱ្យកាន់តែប្រសើរនូវសមត្ថភាពការងារដែលមានស្រាប់ និងអភិវឌ្ឍសមត្ថភាពការងារថ្មី

៤.៥- ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល

# គោលនយោបាយធនធានមនុស្ស

## ៥- ផែនការសកម្មភាព

- ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន
- អ្នកគ្រប់គ្រងមានតួនាទីសំខាន់បំផុតទាំងការគ្រប់គ្រងអង្គភាព និងគុណផលមន្ត្រីរាជការ
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ  សហការសម្របសម្រួល  តម្រង់ទិស តាមដាន និងជួយការអនុវត្តគោលនយោបាយនេះ

# គោលនយោបាយធនធានមនុស្ស

## ៥- ផែនការសកម្មភាព (ត)

- ក្របខ័ណ្ឌគតិយុត្តដែលមានស្រាប់ នឹងត្រូវពិនិត្យឡើងវិញ និងកែសម្រួលតាមការចាំបាច់
- មន្ត្រីរាជការស៊ីវិលដែលពាក់ព័ន្ធនឹងការងារធនធានមនុស្ស នឹងត្រូវបានទទួលការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាព
- ឯកសារគោលនយោបាយ ឬយុទ្ធសាស្ត្រស្តីពីធនធានមនុស្សរបស់ក្រសួងស្ថាប័ន ត្រូវតែធានាឱ្យមានសង្គតិភាពជាមួយគោលនយោបាយនេះ

# គោលនយោបាយធនធានមនុស្ស

## ៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវសហការជាមួយក្រសួងស្ថាប័ន ដើម្បីត្រួតពិនិត្យឡើងវិញរៀងរាល់ឆ្នាំនូវផែនការសកម្មភាពដែលបានកំណត់
- របាយការណ៍លទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវចែកជូនសមាជិកក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងស្ថាប័នសាមី និងមន្ត្រីគ្រប់គ្រងធនធានមនុស្ស សម្រាប់ពិនិត្យ និងកែលំអការអនុវត្ត

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

១.១- កាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន

១.២- កាតព្វគោរពម៉ោងធ្វើការ

១.៣- កាតព្វកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួន

១.៤- កាតព្វគោរពឋានានុក្រម

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.១- កាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន

**មាត្រា ៣៣** នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលបានចែងថា ៖

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោរពបញ្ជាថ្នាក់លើ ដែលបានចាត់ឱ្យទៅបំរើការងារ ទោះបីនៅទីតំបន់ ណាក៏ដោយ ទាំងក្នុងនិងក្រៅប្រទេស។

ហើយ **មាត្រា ៣៤** បន្តសេចក្តីថា ៖

ការឈប់ធ្វើការ ឬ ការខានទៅធ្វើការ ដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នក រាជការនោះ នៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.១- កាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន(ត)

កាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន តម្រូវឱ្យអ្នករាជការរាល់រូបរ៉ាប់រងចំពោះការងារ ឬ សេវាទាំងឡាយដែលរដ្ឋ ( ថ្នាក់លើ) ប្រគល់ជូន ឬ ចាត់តាំងឱ្យអនុវត្តព្រោះការងារដែលអ្នករាជការទទួលអនុវត្ត គឺជាការងាររដ្ឋ ការងារសាធារណៈ មានបែងចែក និង កំណត់ច្បាស់លាស់ចំពោះមន្ត្រីម្នាក់ៗ តម្រូវជាចាំបាច់ឱ្យមន្ត្រីរូបនោះមានវត្តមានជាប្រចាំដើម្បីបំពេញការងារនោះតំណាងអំណាចសាធារណៈ។ បើមិនបានទទួលអនុវត្ត មិនព្រមទទួលអនុវត្ត មិនទៅកាន់កន្លែងអនុវត្តតាមការកំណត់នៃច្បាប់ នោះបានសេចក្តីថា ធ្វើឱ្យមានចន្លោះប្រហោងនៅក្នុងការបំពេញមុខងារសាធារណៈ ដែលសុទ្ធតែជាកំហុសនិងជាការឆ្គាំឆ្គងនៅក្នុងវិជ្ជាជីវៈជាអ្នករាជការបម្រើរដ្ឋ។

# ភារកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- កាតព្វកិច្ចគោរពម៉ោងធ្វើការ

ជាធម្មតា អ្នករាជការទាំងអស់ត្រូវគោរពឱ្យបាននូវពេលម៉ោងធ្វើការរបស់រដ្ឋ ឬរបស់ក្រសួង ស្ថាប័ន អង្គភាពដែលខ្លួននៅបម្រើការងារ ហើយដែលពេលម៉ោងនោះមានកំណត់ច្បាស់លាស់ដោយអនុក្រឹត្យ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន អង្គភាពនោះ។

ប៉ុន្តែក៏មានករណីខ្លះ តម្រូវឱ្យអ្នករាជការបំពេញការងារហួសម៉ោងកំណត់ ឬនៅថ្ងៃសម្រាកជាដើម ព្រោះជាការចាំបាច់ គ្មានអ្នកជំនួស ឬតម្រូវតាមកាលៈទេសៈ ។ល។និង។ល។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- កាតព្វកិច្ចគោរពម៉ោងធ្វើការ(ត)

កាតព្វកិច្ចនេះគឺដើម្បី ធានានិរន្តរភាពនៃសេវាសាធារណៈ ឬជាករណី បន្ទាន់នៃសេវាសាធារណៈ ហើយការខកខាន ព្រងើយកន្តើយ សោះអង្គើយ មិនបានបំពេញនូវកាតព្វកិច្ចនេះ អាចនាំមកនូវផលវិបាកធ្ងន់ធ្ងរផ្សេងៗដល់ កិត្យានុភាពនៃរដ្ឋបាលសាធារណៈផង ដល់អ្នកទទួលអត្ថប្រយោជន៍ពីសេវាសា ធារណៈផង ដែលជាប្រការមួយមិនអាចអត់ឱនបានចំពោះអ្នកខកខានមិនបាន បំពេញកាតព្វកិច្ចនេះ។

# ភារកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- កាតព្វកិច្ចគោរពម៉ោងធ្វើការ(ត)

កាតព្វកិច្ចបំពេញការងារហួសម៉ោងកំណត់ តំរូវចាំបាច់ណាស់ចំពោះអ្នករាជការដែលមានភារកិច្ច បំពេញការងារបច្ចេកទេស ដូចជាគ្រូពេទ្យវះកាត់ដែលត្រូវវះកាត់អ្នកជំងឺជាដើម។

អ្នករាជការទាំងឡាយ មិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬ ដោយ គ្មានមូលហេតុត្រឹមត្រូវ (មាត្រា ៣៤ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល )។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- កាតព្វកិច្ចគោរពម៉ោងធ្វើការ(ត)

ការគោរពម៉ោងធ្វើការបានសេចក្តីថា ការមកធ្វើការត្រឹមត្រូវតាមម៉ោងកំណត់ មិនមានឈប់តាមចិត្តចង់ គ្មានមូលហេតុត្រឹមត្រូវ គ្មានការអនុញ្ញាតជាមុនពីអ្នកទទួលខុសត្រូវ មិនបង្កឱ្យមានចន្លោះប្រហោងក្នុងការបំពេញការងារសាធារណៈ។ ការឈប់មានមូលហេតុ មានការអនុញ្ញាតជាមុន អាចឱ្យថ្នាក់លើចាត់អ្នកជំនួស ឬមានវិធានការដោះស្រាយផ្សេងៗ ដើម្បីធានានិរន្តរភាពនៃរដ្ឋបាល។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- កាតព្វកិច្ចគោរពម៉ោងធ្វើការ(ត)

កាលបើដល់ថ្ងៃកំណត់ត្រូវចូលធ្វើការវិញហើយ អ្នករាជការទាំងអស់ត្រូវតែចូលធ្វើការវិញ ព្រោះនេះជាច្បាប់ ជាកាតព្វកិច្ច ទោះជាការឈប់សម្រាកធម្មតាក្តី ឈប់សម្រាកដោយគ្មានបៀវត្សក្តី។ ការមិនចូលមកបង្ហាញខ្លួន ការមិនមានវត្តមានដើម្បីបន្តបំពេញការងាររបស់ខ្លួន រ៉ាប់រងបន្តនូវសេវារបស់ខ្លួនតាមការកំណត់ អាចចាត់ទុកថាជាការបោះបង់ចោលការងារ ហើយត្រូវទទួលនូវទណ្ឌកម្មផ្សេងៗ ទៅតាមការកំណត់របស់ច្បាប់។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- ភាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.២- ភាតព្វកិច្ចគោរពម៉ោងធ្វើការ(ត)

ការឈប់ញឹកញាប់ពេក ក៏ជាប្រការមួយដែលអ្នករាជការ អ្នកមានមនសិការវិជ្ជាជីវៈគប្បីចៀសវាងដែរ។ ផលវិបាកមិនល្អ នឹងមានជាបឋមមកលើសាមីអ្នករាជការនោះតែម្តង ដែលអាចធ្វើឱ្យអ្នករាជការនោះតាមមិនទាន់ការងារ ឈានទៅរកអសមត្ថភាពក្នុងការងារ។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.៣- កាតព្វកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួន

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ត្រូវតែគោរពបញ្ជាថ្នាក់លើ ដែលបានចាត់ឱ្យទៅបំរើការងារ ទោះបីទីតំបន់ណាក៏ដោយ ទាំងក្នុង និង ក្រៅប្រទេស (មាត្រា៣៣ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល)។

អ្នករាជការបំរើការងាររដ្ឋ ការងារសាធារណៈ មិនត្រូវប្រកែកមិនទទួលតំណែង ឬមិនបំពេញភារកិច្ចដែលចាត់តាំងឡើយ គឺត្រូវទៅកន្លែងធ្វើការ ហើយបំពេញការងារចាត់តាំងនោះ ទោះកន្លែងធ្វើការនោះនៅឆ្ងាយពីលំនៅដ្ឋានផ្ទាល់របស់ខ្លួនក៏ដោយ។ ក្នុងករណីចុងក្រោយនេះ ជាកាតព្វកិច្ច អ្នករាជការត្រូវតែមានលំនៅដ្ឋានប្រចាំនៅកន្លែងធ្វើការនោះទៀត ដើម្បីធានាឱ្យបានល្អនូវនិរន្តរភាពរបស់ការងារសាធារណៈ និង ដោះស្រាយបញ្ហាឱ្យបានជាប់ជាប្រចាំ។

# ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

## ១.៣- កាតព្វកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួន(ត)

ជាគោលការណ៍ អ្នករាជការត្រូវបូជាសកម្មភាពវិជ្ជាជីវៈទាំងមូលរបស់ខ្លួន ចំពោះការងាររដ្ឋ ព្រោះថាក្រៅពីនិរន្តរភាពនៃរដ្ឋបាល នៅមានប្រសិទ្ធភាពនៃការងារមួយទៀតដែលមិនអាចអនុញ្ញាតឱ្យអ្នករាជការប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ " **យកម៉ោងរដ្ឋបាលទៅប្រកបការងារយកកម្រៃផ្ទាល់ខ្លួនផ្សេងទៀត**" (មាត្រា៣៥ ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល )។

ការបំពេញការងារ ឬតួនាទីត្រូវធ្វើដោយសាមីអ្នករាជការផ្ទាល់ខ្លួនឯង មិនមានផ្ទេរទៅឱ្យអ្នកដទៃជំនួសឡើយ លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ ក្នុងករណីខ្លះតែប៉ុណ្ណោះ ព្រោះថា ការចូលបម្រើក្នុងក្របខ័ណ្ឌរដ្ឋ ធ្វើឡើងតាមរយៈការប្រឡងប្រជែង ជ្រើសរើសតាមកម្រិតវប្បធម៌ តាមសមត្ថភាពផ្ទាល់របស់សាមីជន។ ដូច្នេះការងារដែលប្រគល់ជូននោះ គឺមានកំណត់រួចស្រេចទៅ តាមសមត្ថភាពរបស់អ្នករាជការផ្ទាល់រូបនោះតែម្ដង។

# ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

## ១.៣- កាតព្វកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួន(ត)

ក្នុងការបំពេញការងាររបស់ខ្លួន អ្នករាជការមិនត្រូវធ្វើសើៗឱ្យរួចពីដៃ ខ្វះការទទួលខុសត្រូវ ខ្វះប្រសិទ្ធភាពក្នុងការងារនោះទេ តែត្រូវបំពេញឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ ទៅតាមលំដាប់ថ្នាក់នៃការទទួលខុសត្រូវតាមបទបញ្ជាដែលដាក់ចុះសម្រាប់ការអនុវត្តការងារប្រភេទនីមួយៗ។ អ្នករាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាដរាប ក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន (មាត្រា៣៨ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល)។

# ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

## ១.៣- កាតព្វកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួន(ត)

ការទទួលខុសត្រូវអំពីកិច្ចការរបស់ខ្លួន (មាត្រា៣៣ ) និងសមត្ថភាពវិជ្ជាជីវៈ ឬ ប្រសិទ្ធភាពនៃការងារ គឺជាកាតព្វកិច្ចសំខាន់ណាស់ ដែលអ្នករាជការរាល់រូបត្រូវបំពេញឱ្យបាន ហើយដុសខាត់ ច្នៃប្រឌិត បំពាក់បំប៉នឱ្យបានជាប្រចាំ។ ថ្វីបើពុំមានមាត្រាណាមួយច្បាស់លាស់ និយាយអំពីកាតព្វកិច្ចក្នុងការអប់រំបំពាក់បំប៉នជាប្រចាំក៏ដោយ កាតព្វកិច្ចអប់រំបណ្តុះបណ្តាលជាប្រចាំនេះក្លាយជាការជាក់ស្តែងនឹងជាកង្វល់ដ៏ធំមួយរបស់រដ្ឋទៅហើយ។ ការសិក្សាអប់រំជាបន្ត អាចឱ្យអ្នកអនុវត្តការងារតាមទាន់សភាពការណ៍ ហើយគ្រប់គ្រងបាននូវការប្រែប្រួលផ្លាស់ប្តូរ ឬវិវត្តន៍បានយ៉ាងស្រួល។

# ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

## ១.៤- កាតព្វកិច្ចគោរពឋានានុក្រម

រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលដែលមានឋានានុក្រម មានថ្នាក់លើថ្នាក់ក្រោម ហើយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការ ក៏មានការរៀបចំទៅតាមទិសដៅនេះដែរ។ រដ្ឋបាលសាធារណៈភាគច្រើនក្នុងពិភពលោក ជារដ្ឋបាលឋានានុក្រម តម្រូវឱ្យថ្នាក់ក្រោមគោរពតាមថ្នាក់លើជាហូរហែតាមលំដាប់ថ្នាក់។

មាត្រា៣៣ កថាខ័ណ្ឌទី១នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា ៖

អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា ហើយនិងការណែនាំថ្នាក់លើរបស់ខ្លួន។

# ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

## ១.៤- កាតព្វកិច្ចគោរពឋានានុក្រម(ត)

ជាគោលការណ៍ បើថ្នាក់លើចាត់ឱ្យធ្វើអ្វីមួយនោះ ថ្នាក់ក្រោមត្រូវតែគោរពបទបញ្ជានោះ ដោយគ្មានការប្រកែកតវ៉ា។ កាតព្វកិច្ចនេះ មានការតឹងរឹងខ្លាំងណាស់ខាងផ្នែកយោធា។ ប៉ុន្តែអ្នករាជការទាំងអស់ ថ្នាក់ក្រោមក្តី ថ្នាក់លើក្តី "ត្រូវតែគោរព អនុវត្តច្បាប់និងបទបញ្ជា" ដូចគ្នា។ បានសេចក្តីថា ដើម្បីប្រសិទ្ធភាពនៃការងារ និងដើម្បីធានាបាននូវការទទួលខុសត្រូវខ្ពស់ក្នុងការងារ រាល់ការចាត់តាំង ការដាក់ចុះនូវបទបញ្ជា ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីរបស់វា និងទៅតាមគោលការណ៍ដែលកំណត់ដោយច្បាប់ គឺត្រូវគោរពឱ្យបាននូវគោលការណ៍នីតិរដ្ឋ គោរពច្បាប់ អនុវត្តច្បាប់ ធ្វើតាមច្បាប់កំណត់។

## ១- កាតព្វកិច្ចក្នុងពេលបំពេញការងារ

### ១.៤- កាតព្វកិច្ចគោរពឋានានុក្រម(ត)

ចំពោះថ្នាក់លើ  អ្នករាជការរាល់រូប មិនគ្រាន់តែត្រូវគោរពតាមបទបញ្ជាដែលដាក់ចុះប៉ុណ្ណោះទេ  ប៉ុន្តែក៏ត្រូវប្រកាន់យកនូវអាកប្បកិរិយាសមរម្យ ជាកាយវិការគោរពចំពោះថ្នាក់លើផងដែរ។ ប្រការនេះ មិនមានតម្រូវដោយច្បាប់ទេ ប៉ុន្តែជាបែបបទសុជីវធម៌ក្នុងការរស់នៅ ក៏ដូចជាក្នុងទំនាក់ទំនងការងារជាទូទៅដូច្នោះដែរ។

# ភាគពួកិច្ចមន្ត្រីរាជការស៊ីវិល

## ២- ភាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

២.១- ភាតព្វកិច្ចប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស

២.២- ភាតព្វលក្ខណ៍ការ

២.៣- ភាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ

២.៤- ភាតព្វអព្យាក្រឹតក្នុងការងារ

២.៥- ភាតព្វភក្តីភាព

២.៦- ភាតព្វគិតគូរប្រយោជន៍រួម

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.១- កាតព្វកិច្ចប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស

មាត្រា៣៣ កថាខ័ណ្ឌទី២ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា ៖ អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើឱ្យប៉ះពាល់ទៅលើសេចក្ដីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន។

ហើយមាត្រា៣៥ ចំណុច៣ ចែងថា ៖

ហាមឃាត់ជាដាច់ខាត (មិនឱ្យអ្នករាជការ)ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរនៃ អ្នករាជការ។

ទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏អ្នករាជការមិនត្រូវធ្វើអ្វី ឬប្រព្រឹត្តអ្វីដែលនាំឱ្យខូច ឬអាប់ឱនដល់កិត្តិយស និងភាព ថ្លៃថ្នូររបស់ខ្លួនឡើយព្រោះថា បើអ្នករាជការគ្មានកិត្តិយស គ្មានភាពថ្លៃថ្នូរនោះ វាជារូបភាពមិនល្អចំពោះរដ្ឋបាលសាធារណៈ ជាទូទៅ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.១- កាតព្វកិច្ចប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស(ត)

សេចក្ដីថ្លៃថ្នូរនិងកិត្តិយស ស្ដែងចេញពីការប្រព្រឹត្តត្រឹមត្រូវតាមគោលការណ៍កំណត់របស់រដ្ឋ មិនប្រព្រឹត្តអំពើអបាយមុខ មានភាពទៀងត្រង់សុចរិតយុត្តិធម៌ មិនទទួលសំណូក មិនចូលរួមជាមួយអតិថិជន លួចបន្លំតំលៃពន្ធ ....។ល។ និង ។ល។

ភាពថ្លៃថ្នូរនិងកិត្តិយស តម្រូវលើគ្រប់សកម្មភាព និងគ្រប់កាលៈទេសៈទាំងអស់ រួមទាំងសំដីសំដៅ អាកប្បកិរិយា និង ការស្លៀកពាក់តុបតែងខ្លួនជាប្រចាំទៀតផង។ ការប្រព្រឹត្តអំពើ" មិនសមរម្យ " ប្រកបរបរហាមឃាត់ដោយច្បាប់ សុទ្ធតែជាសកម្មភាពដែលអ្នករាជការរាល់រូបត្រូវចៀសវាង ព្រោះនាំឱ្យសាធារណជនវាយតម្លៃមិនល្អដល់មន្ត្រីអ្នករាជការនោះផង និងដល់រដ្ឋបាលតំណាងអំណាចសាធារណៈជាទូទៅផង។

## ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

### ២.១- កាតព្វកិច្ចប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស(ត)

អ្នករាជការទាំងអស់ ត្រូវចៀសវាងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗព្រោះថា អ្នករាជការចំពោះភ្នែកសាធារណជន ជាអ្នកតំណាងប្រយោជន៍រួម តំណាងអំណាចសាធារណៈ តំណាងការគោរពច្បាប់ តំណាងនីតិរដ្ឋ ....។ ការប្រព្រឹត្តមិនល្អក្នុងជីវភាពរស់នៅជាឯកជនក្តី ការប្រព្រឹត្តល្មើសនឹងច្បាប់រដ្ឋនានាក្តី គឺសុទ្ធតែបង្កជារូបភាពមិនល្អដល់អ្នករាជការ ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់អ្នករាជការ និងដល់ជំនឿទុកចិត្តរបស់សាធារណជន លើសកម្មភាពដឹកនាំ និងលើគោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងមូលទៀតផង។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.២- កាតព្វលក្ខណ៍ការ

គឺក្នុងន័យមិនត្រូវធ្វើឱ្យខូច ឬអាប់ឱនកិត្យានុភាពរដ្ឋបាលសាធារណៈនេះហើយ ដែលអ្នករាជការទាំងអស់ត្រូវតែចេះលក្ខណ៍ការ។ គោរពលក្ខណ៍ការ គឺរក្សាបាននូវពាក្យសំដីដែលនិយាយចេញទៅ ឬសរសេរចេញទៅដោយប្រយ័ត្នប្រយែង មិននិយាយ ឬសរសេរនូវអ្វីដែលឱ្យប៉ះពាល់ដល់កិត្តិយស កិត្យានុភាពរបស់ក្រសួងស្ថាប័ន អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួនឡើយ។

កាតព្វកិច្ចនេះតម្រូវចាំបាច់ណាស់ចំពោះអ្នករាជការ អ្នកមានសិទ្ធិបោះឆ្នោត និងចូលរួមយុទ្ធនាការបោះឆ្នោត  គឺថាត្រូវចៀសវាងជាដាច់ខាតកុំយករឿងការងាររដ្ឋបាលដែលជារឿងអព្យាក្រឹត រឿងរួម ទៅប្រឡូកប្រឡាក់ជាមួយរឿងនយោបាយ រឿងបក្សពួកឱ្យសោះ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.២- កាតព្វលក្ខណ៍ការ(ត)

ការអនុវត្តហួសព្រំដែននូវសេរីភាពក្នុងការបញ្ចេញមតិ មិនគោរពលក្ខណ៍ការនៃការងារ សុទ្ធតែជាកំហុស និងជាអំពើឆ្គាំឆ្គងក្នុងវិជ្ជាជីវៈជាអ្នករាជការ  ហើយអាចទទួលទោសជាប់ពន្ធនាគារ ដែលមានចែងនៅក្នុងមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ស្តីពីការបរិហារកេរ្តិ៍ និងការជេរប្រមាថ ទៀតផង។

គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្តនូវអំពើជាកំណត់ណាមួយដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំឱ្យកើតស្មៅហ្មងដល់ជននោះ គឺចាត់ជាការបរិហារកេរ្តិ៍។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.២- កាតព្វលក្ខណ៍ការ(ត)

គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានកំណត់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ។

ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ......ត្រូវផ្តន្ទាទោសដាក់គុកពី ៨ ថ្ងៃ ដល់ ១ ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ ពី ១.០០០.០០០រៀលទៅ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៣- កាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ

លក្ខណ៍ការ ឬការប្រយ័ត្នប្រយែងពាក្យសំដី មានលក្ខណៈខុសគ្នាពីការសំងាត់វិជ្ជាជីវៈ។ ការមិនចេះគោរពលក្ខណ៍ការនៃការងារ បង្កើតឱ្យមានរូបភាពមិនល្អដល់រដ្ឋបាល នាំឱ្យមានការមិនជឿទុកចិត្តដល់ការដឹកនាំរបស់រដ្ឋ របស់អ្នកដឹកនាំរដ្ឋបាលជាទូទៅ។ អ្នករាជការធ្វើការនៅកន្លែងណា មិនត្រូវនិយាយអាក្រក់ពីអ្នកដឹកនាំកន្លែងនោះឡើយ តែត្រូវមានភារកិច្ច កាតព្វកិច្ចរក្សា ការពារកិត្តិសព្ទរបស់រដ្ឋបាលនៅទីនោះ។ នេះឈ្មោះថា គោរពបាននូវលក្ខណ៍ការនៃការងារ។ ចំពោះកាតព្វកិច្ចគោរពការសំងាត់ វិជ្ជាជីវៈវិញ គឺតំរូវឱ្យអ្នករាជការទាំងអស់ធ្វើយ៉ាងណាកុំឱ្យបែកធ្លាយចេញទៅក្រៅ នូវរាល់ហេតុការណ៍ គ្រប់ពត៌មានឬឯកសារ ទាំងឡាយណា ដែលខ្លួនបានដឹងបានឮនៅក្នុងការងារ ឬក្នុងពេលបំពេញការងារ បើសិនជាគ្មានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួន ឬ ក្រៅសមត្ថកិច្ចរបស់ខ្លួន ឬគ្មានការកំណត់ដោយច្បាប់។

## ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

### ២.៣- កាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ(ត)

មាត្រា៣៥ ចំណុច៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា៖ ត្រូវហាមឃាត់ជាដាច់ខាត ដល់អ្នករាជការ នូវការបោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយ ពត៌មាន ដែលមានពាក់ព័ន្ធ នៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័ន ដែលសាមីខ្លួននៅក្រោមឱវាទ។

ការសំងាត់វិជ្ជាជីវៈ ហាក់ដូចជាមានលក្ខណៈផ្ទុយនឹងគោលការណ៍តម្លាភាពនៃរដ្ឋបាលប្រជាធិបតេយ្យ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងមាត្រា៣៥ នៃច្បាប់រដ្ឋធម្មនុញ្ញថា ៖ "សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងម៉ត់ចត់ពីអង្គការរដ្ឋ"។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៣- កាតព្វកិច្ចគោរពការសម្ងាត់វិជ្ជាជីវៈ(ត)

ទោះជាយ៉ាងណាក្តី នៅមានការងារមួយចំនួនដែលរដ្ឋត្រូវរក្សាការសំងាត់ ជាពិសេសគឺព័ត៌មានដែលអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងកិត្យានុភាពរបស់សង្គម និងប្រទេសជាតិ........... ហើយព័ត៌មានខ្លះទៀតដែលមិនទាន់ដល់ពេលវេលានឹងធ្វើការផ្សព្វផ្សាយ ក៏មិនត្រូវធ្វើការផ្សព្វផ្សាយដែរ។ ការសំងាត់វិជ្ជាជីវៈ មិនត្រឹមតែត្រូវអនុវត្តចំពោះសាធារណជនប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តចំពោះសហសេវិកអ្នករួមការងារជាមួយគ្នា ក្នុងរដ្ឋបាលដែលមិនមានភារកិច្ចត្រូវដឹងនូវការងារនោះទៀតផងដែរ។

## ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

### ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ

មាត្រា៣៧ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា៖ មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាត នូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនយោបាយ ដូចខាងក្រោម៖

- ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ។
- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។

ការប្រព្រឹត្តផ្ទុយនឹងមាត្រានេះ ចាត់ទុកជាកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ(ត)

មន្ត្រីរាជការ គឺជាអ្នកបម្រើជួបម្រើប្រយោជន៍សាធារណៈ ប្រយោជន៍រួម មិនមែនប្រយោជន៍បុគ្គល ឬក្រុមបក្សពួកណាមួយឡើយ។ ដូច្នេះក្នុងការបំពេញការងារ ក៏ដូចជាក្នុងការបម្រើអតិថិជនជាប្រជាពលរដ្ឋ ជាអ្នកទទួលសេវារដ្ឋ អ្នករាជការទាំងអស់ ត្រូវប្រកាន់ឱ្យខ្ជាប់នូវភាពអព្យាក្រឹត មិនលំអៀង មិនអគតិ។ ភាពមិនអព្យាក្រឹតអាចនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិត និងអនាគតរបស់អ្នកទទួលសេវារដ្ឋ។ ឧទាហរណ៍ គ្រូពេទ្យវះកាត់ដែលធ្វើការវះកាត់ ឬព្យាបាលអ្នកជម្ងឺដោយប្រកាន់បក្សពួក រើសអើង ...ឬ គណៈមេប្រយោគដែលធ្វើការប្រលងជ្រើសរើស ឬកែវិញ្ញាសាបេក្ខជន ដោយមិនគោរពគោលការណ៍វិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ។ល។ និង ។ល។

## ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

### ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ(ត)

ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ក៏បានហាមប្រាមជាដាច់ខាតផងដែរដល់អ្នករាជការក្នុងពេលបំពេញការងារ មិនឱ្យយកឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួន ទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬ ដើម្បីសំឡុតគំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ (មាត្រា៣៥ចំនុច២ )។ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៥៧ស្តីពីអំពីរំលោភលើសិទ្ធិបុគ្គល បានចែងថា ៖

គ្រប់ភ្នាក់ងារសាធារណៈ រួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរួញរាទៅលើសិទ្ធិ បូរណភាព បុគ្គល......នឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ(ត)

ការប្រើប្រាស់មុខងារ សម្ភារៈនិងបុគ្គលិករដ្ឋ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនជាពិសេសដើម្បីសកម្មភាពនយោបាយ គឺជាប្រការ ដែលផ្ទុយនឹងគោលការណ៍អព្យាក្រឹតភាពមួយទៀត នៃរដ្ឋបាលសាធារណៈ ហើយក៏ត្រូវហាមប្រាមជាដាច់ខាតដែរ (មាត្រា ៣៧)។ ក្រៅពីទោសទណ្ឌខាងវិន័យ អ្នកប្រព្រឹត្តល្មើស អាចជាប់ចោទពីបទតែបំបាត់ទៀតផង។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ(ត)

មាត្រា៣៧ ( ច្បាប់ព្រហ្មទណ្ឌអន្តរកាល ) ៖

១-ជនជាតំណាងជាប់ឆ្នោត អ្នករដ្ឋការស៊ីវិល និងយោធាទាំងអស់.......ដែលក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងារនេះ បានយកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន លក់ដូរលក់ជួលតែបំបាត់ជាប្រយោជន៍ខ្លួន ឬជាប្រយោជន៍តតិយជនណាមួយនូវទ្រព្យសម្បត្តិ សេវាកម្មប្រាក់កាស បុគ្គលិក ប្រយោជន៍ ឯកសារ សេចក្តីអនុញ្ញាត ឬមុខងារដែលជារបស់សមូហភាពណាមួយ ធ្វើជាកម្មសិទ្ធិ ឬជាសិទ្ធិអាស្រ័យផល ត្រូវមានទោសពីបទឧក្រិដ្ឋ តែបំបាត់សម្បត្តិសាធារណៈ ហើយត្រូវផ្តន្ទាទោសដាក់គុកពី ៣ ឆ្នាំ ទៅ ១០ ឆ្នាំ ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៤- កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ(ត)

មាត្រា៣៧ (ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ៖

២-ជនណាដែលបានប្រព្រឹត្តបទល្មើសខាងលើនោះ នឹងអាចត្រូវតុលាការដកហូតមុខងារចេញពីអាណត្តិនៃការជ្រើសតាំងរបស់ខ្លួន ហើយម្យ៉ាងទៀត នឹងអាចត្រូវហាមឃាត់មិនឱ្យឈរឈ្មោះបោះឆ្នោត ឬមិនឱ្យកាន់មុខតំណែងដែលមានការទទួលខុសត្រូវណាមួយក្នុងរដ្ឋបាលសាធារណៈ ក្នុងរយៈពេលពីរឆ្នាំក្រោយពីបានរងទោសរបស់ខ្លួនរួចហើយ។

## ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

### ២.៥- កាតព្វភក្តីភាព

ជាគោលការណ៍ ការចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ ធ្វើឡើងតាមរយៈការប្រឡងប្រជែង គ្មានការបង្ខិតបង្ខំ គឺជាការជ្រើសរើសប្រកបដោយការគិតគូរច្បាស់លាស់ពីសំណាក់អ្នករាជការម្នាក់ៗ។ ថ្វីបើប្រការនេះមិនមានចែងច្បាស់លាស់នៅក្នុងច្បាប់សហលក្ខន្តិកៈ ឬលក្ខន្តិកៈដោយឡែក ប៉ុន្តែអ្នករាជការរាល់រូប ត្រូវតែបំពេញនូវកាតព្វកិច្ចភក្តីភាពនេះ ដែលជាហេតុការណ៍ប្រត្យក្ស តម្រូវជាទូទៅដោយរដ្ឋធម្មនុញ្ញត្រង់មាត្រា៤ ដែលកំណត់ថា ៖ " បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ ៖ " ជាតិ សាសនា ព្រះមហាក្សត្រ " ។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៥- កាតព្វភក្ដីភាព(ត)

អ្នករាជការទាំងអស់ត្រូវតែមានភក្ដីភាពចំពោះ ជាតិ សាសនា និង ព្រះមហាក្សត្ររបស់ខ្លួន។ មន្ត្រីជាន់ខ្ពស់ទាំងឡាយ ត្រូវបានរដ្ឋប្រគល់ការទុកចិត្តចាត់តាំងឱ្យបំពេញភារកិច្ចដែលជាអាយុជីវិតប្រទេសជាតិ ជាទីទុកចិត្តខ្ពស់បំផុតរបស់រដ្ឋ ដូច្នេះចាំបាច់ត្រូវតែមានកាតព្វកិច្ចស្មោះត្រង់ ភក្ដីជានិច្ចចំពោះប្រទេសជាតិ ចំពោះគោលនយោបាយ និងមាគ៌ាដឹកនាំរបស់រដ្ឋ ចំពោះផលប្រយោជន៍រដ្ឋ និងចំពោះអ្នកដែលចាត់តាំងប្រគល់ភារកិច្ចឱ្យខ្លួន។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៥- កាតព្វកិច្ចភក្ដីភាព(ត)

ភក្ដីភាពនេះ ជាកាតព្វកិច្ចចាំបាច់សម្រាប់អ្នករាជការរាល់រូបគ្រប់លំដាប់ថ្នាក់។ អ្នកដឹកនាំអង្គភាពត្រូវមានភក្ដីភាពចំពោះក្រសួង ចំពោះថ្នាក់ដឹកនាំក្រសួង ឯអ្នកដឹកនាំក្រសួងត្រូវមានភក្ដីភាពចំពោះរាជរដ្ឋាភិបាល ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាល ហើយអ្នករាជការដទៃទៀតត្រូវមានភក្ដីភាពចំពោះថ្នាក់លើ ដែលខ្លួនស្ថិតក្រោមឱវាទជាបន្តបន្ទាប់។

ការខ្វះខាត ខកខានមិនបានបំពេញនូវកាតព្វកិច្ចនេះ នាំមកនូវសេចក្ដីអន្តរាយបាត់បង់មុខតំណែងផ្ទាល់ខ្លួនរបស់អ្នករាជការរូបនោះផង ហើយក៏ធ្វើឱ្យមានការមិនទុកចិត្ត បែកបាក់ប្រេះឆាសាមគ្គីភាពផ្ទៃក្នុងរដ្ឋបាលជាទូទៅទៀតផង។

# ២- កាតព្វកិច្ចរួម ក្នុង និង ក្រៅពេលបំពេញការងារ

## ២.៦- កាតព្វគិតគូរប្រយោជន៍រួម

មាត្រា៣៥ ចំណុច៤ នៃច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវប្រការដូចខាងក្រោម៖

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬ ដោយប្រយោល។ ប្រការនេះ  គឺដើម្បីចៀសវាងមិនឱ្យអ្នករាជការប្រើឥទ្ធិពល តួនាទី ពេលម៉ោងរដ្ឋ អង្គភាព បុគ្គលិក សេវា ទ្រព្យសម្បត្តិរដ្ឋ ឬ លួចបន្លំ កេងប្រវ័ញ្ចរបស់ទាំងនោះ ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ឬធ្វើជាសម្បត្តិផ្ទាល់ខ្លួន នាំឱ្យបាត់បង់អព្យាក្រឹតភាពក្នុងការងារ ធ្វើខ្លួនឱ្យក្លាយជារណបនៃប្រយោជន៍ផ្ទាល់ខ្លួន គិតគូរនិងសម្រេចកិច្ចការក្នុងភាពលំអៀង អគតិ ដែលជាហេតុធ្វើឱ្យខូចប្រយោជន៍សាធារណៈ។ អ្នករាជការទាំងអស់គប្បីមានមនសិការវិជ្ជាជីវៈខ្ពស់ ស្នេហាជាតិ ស្នេហាប្រជាជន យកប្រយោជន៍ជាតិ ប្រយោជន៍រួមជាធំ ចៀសវាងការបម្រើការងារដើម្បីបុណ្យសក្តិ ទ្រព្យធនផ្ទាល់ខ្លួន ធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍សមូហភាព។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ៣- កាតព្វកិច្ចក្រៅម៉ោងធ្វើការ

៣.១- កាតព្វកិច្ចមិនត្រូវប្រកបមុខរបរបន្ថែមត្រួតលើមុខងារ មាត្រា៣៥ ចំណុច ៦ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលចែងថា ត្រូវហាមឃាត់ជាដាច់ខាត ដល់អ្នករាជការនូវប្រការដូចខាងក្រោម ៖
៦- ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់។ករណីវិសមិតភាពនៃការងាររបស់អ្នករាជការក្នុងមុខងារសាធារណៈ មានកំណត់ច្បាស់លាស់ទៅតាមករណីនីមួយៗនៅក្នុងច្បាប់ដោយឡែកៗ ដូចជាច្បាប់បោះឆ្នោតជាដើម។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ៣- កាតព្វកិច្ចក្រៅម៉ោងធ្វើការ(ត)

ការប្រកបមុខរបរបន្ថែមត្រួតលើមុខងារប្រចាំរបស់អ្នករាជការ មិនអាចឱ្យ អ្នករាជការរូបនោះ មានលទ្ធភាពគ្រប់គ្រាន់នឹងបំពេញកាតព្វកិច្ចទាំងឡាយខាងលើ ដែលតំរូវដោយរដ្ឋបាលសាធារណៈបានឡើយ ។ ម្យ៉ាងទៀត ការងារទាំងពីរនោះអាចមានលក្ខណៈ និងផលប្រយោជន៍ ឬទិសដៅផ្ទុយគ្នា មិនអាចឱ្យអ្នកទទួលបំពេញគោរពបាននូវ គោលការណ៍នៃការងារសាធារណៈ ។ ក្នុងករណីខ្លះ មុខរបរ ឬសកម្មភាពរបស់សហពន្ធ័ ក៏អាចមានផលប៉ះពាល់អវិជ្ជមានដល់ការងារសាធារណៈរបស់អ្នករាជការដែរ ដែលអ្នករាជការប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ គប្បីពិនិត្យពិចារណា ចៀសវាងកុំឱ្យមាន។

# ភាតព្វកិច្ចមន្ត្រីរាជការស៊ីវិល

## ៣- កាតព្វកិច្ចក្រៅម៉ោងធ្វើការ(ត)

ក្រៅពីកាតព្វកិច្ចដែលរៀបរាប់ខាងលើ អ្នករាជការទាំងអស់ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវតែគោរពរដ្ឋធម្មនុញ្ញ និង ត្រូវគោរពច្បាប់របស់រដ្ឋដូចៗគ្នា (មាត្រា៤៩ រដ្ឋធម្មនុញ្ញ)។ ដូច្នេះអ្នករាជការដែលជាពលរដ្ឋ និងជាអ្នកដែលមានភារកិច្ចបម្រើរដ្ឋ បម្រើប្រជាពលរដ្ឋ ត្រូវមានកាតព្វកិច្ចបំពេញក្នុងនាមជាពលរដ្ឋផង ក្នុងនាមជាអ្នករាជការផង បានសេចក្តីថាត្រូវគោរពច្បាប់ទាក់ទង នឹងមុខងារសាធារណៈរបស់ខ្លួនផង និងច្បាប់រដ្ឋទូទៅដទៃផង។

# ការពិនិត្យប្រតិបត្តិការក្រសួងស្ថាប័នឡើងវិញ

## OPERATIONAL REVIEW

១- និយមន័យ

២- ប្រភេទនៃការពិនិត្យប្រតិបត្តិការឡើងវិញ

៣- មូលហេតុដែលត្រូវធ្វើការពិនិត្យប្រតិបត្តិការឡើងវិញ

៤- ពេលវេលាត្រូវធ្វើការពិនិត្យប្រតិបត្តិការឡើងវិញ

៥- ការត្រៀមរៀបចំការពិនិត្យប្រតិបត្តិការឡើងវិញ

៦- ជម្រើសក្នុងការអនុវត្តការពិនិត្យប្រតិបត្តិការឡើងវិញ

៧- បទពិសោធន៍នៃការពិនិត្យប្រតិបត្តិការឡើងវិញ

៨- ការអនុវត្តការពិនិត្យប្រតិបត្តិការឡើងវិញ






# ការពិនិត្យប្រតិបត្តិការឡើងវិញ

១- និយមន័យ៖

- ការពិនិត្យប្រតិបត្តិការឡើងវិញគឺជានីតិវិធី ជាវិធីសាស្រ្ត សម្រាប់ធ្វើស្វ័យវាយតម្លៃ និងឈានទៅសម្រេចចិត្តធ្វើការផ្លាស់ប្តូរចាំបាច់ណាមួយ ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ
- ការពិនិត្យប្រតិបត្តិការឡើងវិញ គឺជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័ន






# ការពិនិត្យប្រតិបត្តិការឡើងវិញ

២- ប្រភេទនៃការពិនិត្យប្រតិបត្តិការឡើងវិញមាន០៣៖

- ការពិនិត្យឡើងវិញនូវ **មុខងារ**
- ការពិនិត្យឡើងវិញនូវ **រចនាសម្ព័ន្ធ**
- ការពិនិត្យឡើងវិញនូវ **អភិក្រមការងារ**


មុខងារ
Functions
រចនាសម្ព័ន្ធ
Structure
អភិក្រម
Process
លទ្ធផលសម្រេចបាន
រយៈពេលអនុវត្តការងារ

# ការពិនិត្យប្រតិបត្តិការឡើងវិញ

៣- មូលហេតុដែលត្រូវធ្វើការពិនិត្យប្រតិបត្តិការឡើងវិញ៖

- ធានាសង្គតិភាពរវាង មុខងារ រចនាសម្ព័ន្ធ និង អភិក្រមការងារ
- ធានាឱ្យប្រតិបត្តិការរបស់ស្ថាប័ន នៅតែមានប្រសិទ្ធភាព

# ការពិនិត្យប្រតិបត្តិការឡើងវិញ

## ៤- ពេលវេលាត្រូវពិនិត្យប្រតិបត្តិការឡើងវិញ៖

### ៤.១ - ការពិនិត្យឡើងវិញនូវ **មុខងារ៖**

- ស្ថានភាពរបស់អង្គភាព មានការវិវត្តខុសពីប្រក្រតី
- អាណត្តិរបស់ស្ថាប័ន ត្រូវបានផ្លាស់ប្តូរ
- ផែនការយុទ្ធសាស្ត្រថ្មី ត្រូវបានបង្កើត
- មុខងារថ្មី ត្រូវបានប្រគល់

# ការពិនិត្យប្រតិបត្តិការឡើងវិញ

## ៤- ពេលវេលាត្រូវពិនិត្យប្រតិបត្តិការឡើងវិញ៖

### ៤.២ - ការពិនិត្យឡើងវិញនូវ **រចនាសម្ព័ន្ធ៖**

- មានការផ្លាស់ប្តូរមុខងារ
- ការដំឡើងថ្នាក់អង្គភាព
- មានការអនុវត្តសកម្មភាពជាន់គ្នា
- មានការខ្វះចន្លោះមិនបានអនុវត្តមុខងារណាមួយ

# ការពិនិត្យប្រតិបត្តិការឡើងវិញ

## ៤- ពេលវេលាត្រូវពិនិត្យប្រតិបត្តិការឡើងវិញ៖

### ៤.៣ - ការពិនិត្យឡើងវិញនូវ **អតិថិជន**

- ការិយាធិបតេយ្យស្មុគស្មាញ
- ភាពមិនពេញចិត្តចំពោះសេវាដែលបានផ្តល់
- មានការផ្លាស់ប្តូរ ឬកែសម្រួលរចនាសម្ព័ន្ធ

# ការពិនិត្យប្រតិបត្តិការឡើងវិញ

## ៥- ការត្រៀមរៀបចំការពិនិត្យប្រតិបត្តិការឡើងវិញ៖

- ថ្នាក់ដឹកនាំត្រូវមានការតាំងចិត្ត និងផ្តល់ការគាំទ្រពេញទំហឹងទៅលើដំណើរការ
- បង្កើតក្រុមការងារដឹកនាំ & គ្រប់គ្រងដំណើរការ
- បង្កើតក្រុមការងារ( ដឹកនាំគ្រប់គ្រង&បច្ចេកទេស )
- ប្រកាសតែងតាំងក្រុមការងារជាផ្លូវការ និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញភារកិច្ច

# ការពិនិត្យប្រតិបត្តិការឡើងវិញ

## ៦- ជម្រើសក្នុងការអនុវត្ត៖

- ប្រើប្រាស់ធនធានផ្ទាល់របស់ក្រសួងស្ថាប័ន
- ស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ

# ៧. បទពិសោធន៍នៃការពិនិត្យប្រតិបត្តិការឡើងវិញ

## ៧.១- បទពិសោធន៍ជាលក្ខណៈអន្តរជាតិ

- ភាគច្រើនផ្តោតការយកចិត្តទុកដាក់លើផ្នែកឯកជន ជាងវិស័យសាធារណៈ
- ប្រមូលផ្តុំព័ត៌មាននានាពាក់ព័ន្ធនឹងប្រតិបត្តិការរបស់អង្គភាព
- វិភាគព័ត៌មានដោយល្អិតល្អន់ ដើម្បីរកឱ្យឃើញនូវជម្រើសសម្រាប់កែលំអ
- ការពិនិត្យប្រតិបត្តិការឡើងវិញ គឺជាទម្រង់នៃការស្វែងរកព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីជួយដល់ការរៀបចំឡើងវិញ និងព្រឹងស្ថាប័ន តាមរយៈការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃស្ថាប័ន

## ៧. បទពិសោធន៍នៃការពិនិត្យប្រតិបត្តិការឡើងវិញ

### ៧.២- បទពិសោធន៍របស់បណ្តាក្រសួងស្ថាប័ន

- ការពិនិត្យប្រតិបត្តិការឡើងវិញ ត្រូវមានការណែនាំច្បាស់លាស់ និងវិធីសាស្ត្រសមស្រប
- ផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ មុននឹងអនុវត្ត
- បង្ហាញគោលបំណង និងគោលដៅឱ្យបានច្បាស់លាស់
- ត្រូវមានធនធានមនុស្ស និង ហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ដំណើរការ
- ត្រូវមានការប្តេជ្ញាចិត្តម៉ឺងម៉ាត់ចំពោះរាល់សំណើនៃការផ្លាស់ប្តូរ

# ៨. ការអនុវត្តការពិនិត្យប្រតិបត្តិការឡើងវិញ

- បង្កើតក្រុមការងារគ្រប់គ្រង និងដឹកនាំដំណើរការ
- បង្កើតក្រុមការងារបច្ចេកទេស
- សិក្សាស្វែងយល់ឱ្យបានច្បាស់លាស់លើខ្លឹមសារឯកសារទាំងអស់
- រៀបចំផែនការការងារ
- រៀបចំតារាងកាលវិភាគនៃការពិនិត្យឡើងវិញ
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវផែនការពិនិត្យប្រតិបត្តិការឡើងវិញ

# ការអនុវត្ត ការពិនិត្យប្រតិបត្តិការឡើងវិញ



# ប្រព័ន្ធលាភការ

## លក្ខណៈទូទៅ

- គឺជាតម្លៃសមស្របនៃការងារដែលរដ្ឋត្រូវផ្ដល់ដល់មន្ត្រីរាជការដែលបំពេញមុខងារសាធារណៈមួយដ៏ពេញលេញក្នុងការផ្ដល់សេវានានារបស់រដ្ឋ ហើយដែលត្រូវកំណត់ដោយច្បាប់
- ធាតុផ្សំនៃប្រព័ន្ធលាភការ មាន៖ បៀវត្សមូលដ្ឋាន, ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀត
- ប្រព័ន្ធលាភការ តែងតែប្រែប្រួលទៅតាមស្ថានភាពសេដ្ឋកិច្ច, នយោបាយ និង សង្គម

## លក្ខណៈទូទៅនៃប្រព័ន្ធលាភការ(ត)

ឧទាហរណ៍៖

- នៅប្រទេសបារាំង ពីឆ្នាំ១៩៤៨ ដល់ ១៩៨៥ មានការផ្លាស់ប្តូរ ចំនួន ៩ ដងទៅលើ ការកំណត់សន្ទស្សន៍, ប្រាក់បំណាច់, ប្រាក់រង្វាន់, ប្រាក់ពន្ធ...
- ឆ្នាំ១៩៤៨ សន្ទស្សន៍បៀវត្សគឺ៖

    **ឃ** ពី ១០០ ដល់ ១៨៥

    **គ** ពី ១៣០ ដល់ ២៥០

    **ខ** ពី ១៨៥ ដល់ ៣៦០

    **ក** ពី ២២៥ ដល់ ៨០០

## លក្ខណៈទូទៅនៃប្រព័ន្ធលាភការ(ត)

ឧទាហរណ៍៖

- ឆ្នាំ១៩៥០ ផ្លាស់ប្តូរប្រាក់ពន្ធលើបៀវត្ស
- ឆ្នាំ ១៩៥៥ ផ្លាស់ប្តូរសន្ទស្សន៍ឡើងវិញ
- ឆ្នាំ ១៩៥៧ បង្កើតឱ្យមានប្រាក់រង្វាន់តាមឋានានុក្រម
- ឆ្នាំ ១៩៦១ ផ្លាស់ប្តូរប្រាក់បំណាច់ និងសន្ទស្សន៍បៀវត្សតាមរបៀប Plan de Guillaumat
- ឆ្នាំ ១៩៦២, ១៩៦៨, ១៩៧០, ១៩៧២ និង ១៩៨៣ ផ្លាស់ប្តូរតារាងខ្ទង់សន្ទស្សន៍...

# លក្ខណៈទូទៅនៃប្រព័ន្ធលាភការ(ត)

នៅកម្ពុជា ចាប់តាំងពីបានបោះពុម្ពក្រដាសប្រាក់ ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៨០ មកទល់១៩៩៩ មានការប្រែប្រួលជាច្រើនលើក៖

- ក្រោយថ្ងៃរំដោះ ១៩៧៩ មកដល់មុនពេលមានក្រដាសប្រាក់ មានការឧបត្ថម្ភជាគ្រឿងឧបភោគ បរិភោគសុទ្ធសាធ
- ចាប់ពីមានក្រដាសប្រាក់ រដ្ឋបានផ្តល់ជាប្រាក់ឧបត្ថម្ភ គួបផ្សំនឹងគ្រឿងឧបភោគ បរិភោគ និងលក់ទំនិញខ្លះជូនតាមតម្លៃរដ្ឋ
- ឆ្នាំ១៩៨៣ រៀបចំកាំប្រាក់ជា៣ ប្រភេទ ក ខ គ បូកនឹងប្រាក់តំបន់ និងប្រាក់បំណាច់ទទួលខុសត្រូវ(សេចក្តីសម្រេចលេខ ៨៩ សសរ-ខែ១០/១៩៨៣)
- ឆ្នាំ ១៩៩២ ផ្តល់លាភការជាសាច់ប្រាក់ទាំងស្រុង

# ប្រព័ន្ធបៀវត្សចាស់

សមាសភាគនៃប្រព័ន្ធលាភការដែលបង្កើតនៅឆ្នាំ១៩៨៣ ៖

១. កាំប្រាក់មាន៣ប្រភេទគឺ **ក ខ** និង **គ**

- ប្រភេទនីមួយៗ បៀវត្សទាបបំផុត និង ខ្ពស់បំផុត ខុសគ្នា ២,៥ ដង
  (ឧទាហរណ៍: ខ.៤.១ ទៅ ខ.១.៦)
- បៀវត្សទាបបំផុតនៅប្រភេទ គ និង ខ្ពស់បំផុតនៅប្រភេទ ក ខុសគ្នា ៤,៥ ដង
  (ឧទាហរណ៍: គ.៤.១ ទៅ ក.១)

២. ប្រាក់បំណាច់តំបន់

(ដូចជាតំបន់ដាច់ស្រយាល, តំបន់គ្រុនចាញ់...)

៣. ប្រាក់បំណាច់ទទួលខុសត្រូវ

(ដូចជា នាយកសាលា, នាយកមន្ទីរពេទ្យ...)

# ប្រព័ន្ធបៀវត្សចាស់

សេចក្ដីសម្រេចលេខ ៨៩ សសរ ចុះថ្ងៃទី១០/១០/១៩៨៣

ប្រព័ន្ធបៀវត្ស ត្រូវបានរៀបចំជា ៣ តារាង៖

## តារាង ក ខ និង គ

**១-តារាង ក ៖ បៀវត្សកម្មាភិបាលដឹកនាំ**

- **ក**.I : ផ្នែកអង្គការបក្សប្រជាជនបដិវត្តកម្ពុជា
- **ក**.II : ផ្នែកអង្គការរដ្ឋបាល
- **ក**.III : ផ្នែកអង្គការមហាជន

**២-តារាង ខ ៖ បៀវត្សកម្មាភិបាល បុគ្គលិកបច្ចេកទេស និងរដ្ឋបាល**

**៣-តារាង គ ៖ បៀវត្សកម្មករបច្ចេកទេស និង ពលករសាធារណៈ**

| តារាង | ប្រភេទ | កាំប្រាក់ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| ក | ក I | | | | | | | |
| | ក II | | | | | | | |
| | ក III | | | | | | | |
| ខ | ខ I | | | | | | | |
| | ខ II | | | | | | | |
| | ខ III | | | | | | | |
| | ខ IV | | | | | | | |
| គ | គ I | | | | | | | |
| | គ II | | | | | | | |
| | គ III | | | | | | | |
| | គ IV | | | | | | | |

# ឥ.I : កម្មាភិបាលដឹកនាំផ្នែកអង្គការបក្សប្រជាជនបដិវត្តកម្ពុជា - មាន ៨ ប្រភេទ

| តារាង | ប្រភេទ | កាំ | | | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | |
| ឥ.I | ១ | | | | - អគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា |
| | ២ | | | | - សមាជិកការិយាល័យនយោបាយនៃគ/ការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា<br>- លេខាអចិន្ត្រៃយ៍មជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា |
| | ៣ | | | | - ប្រធានគណៈ និង ប្រធានខុទ្ទកាល័យមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា |
| | ៤ | | | | - អនុប្រធានគណៈចំណុះកម្មាធិការមជ្ឈិមបក្ស<br>- អនុប្រធានខុទ្ទកាល័យមជ្ឈិមបក្ស<br>- លេខាគណៈកម្មាធិការបក្សប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៥ | | | | - អនុលេខាគណៈកម្មាធិការបក្សប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៦ | | | | - ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ គ/ការមជ្ឈិមបក្សប្រជាជនបដិវត្តកម្ពុជា<br>- សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការបក្សប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៧ | | | | - អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរ គណៈកម្មាធិការមជ្ឈិមបក្ស<br>- ប្រធានគណៈកម្មការនៃគណៈកម្មាធិការបក្សប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៨ | | | | - អនុប្រធានគណៈកម្មការនៃគណៈកម្មាធិការបក្សប្រជាជនបដិវត្តខេត្ត ក្រុង |

# ភ.II : កម្មាភិបាលដឹកនាំផ្នែកអង្គការរដ្ឋបាល - មាន ១១ ប្រភេទ

| តារាង | ប្រភេទ | កាំ | | | ឋានៈ/តួនាទី |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | |
| ភ.II | ១ | | | | - ប្រធានក្រុមប្រឹក្សារដ្ឋ<br>- ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី, - នាយករដ្ឋមន្ត្រី<br>- ប្រធានរដ្ឋសភា |
| | ២ | | | | - អនុប្រធានក្រុមប្រឹក្សារដ្ឋ, - ឧបនាយករដ្ឋមន្ត្រី<br>- អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី |
| | ៣ | | | | - អគ្គលេខាធិការ និង សមាជិកក្រុមប្រឹក្សារដ្ឋ, - ទេសរដ្ឋមន្ត្រី<br>- រដ្ឋមន្ត្រី<br>- អនុប្រធាន និង អគ្គលេខាធិការរដ្ឋសភា |
| | ៤ | | | | - ក.II.៤.៣ = ប្រធានអគ្គនាយកដ្ឋាន, - រដ្ឋលេខាធិការ និងថ្នាក់ស្មើ<br>- ក.II.៤.២ និង ក.II.៤.១ = អនុរដ្ឋមន្ត្រី ឧបការីរដ្ឋមន្ត្រីប្រធាន<br>គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៥ | | | | - អនុប្រធានអគ្គនាយកដ្ឋាន<br>- អនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង |

| តារាង | ប្រភេទ | កាំ | | | ឋានៈ/តួនាទី |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | |
| ក.II | ៦ | | | | - ប្រធាននាយកដ្ឋាន ប្រធានមន្ទីរក្រសួង និងអគ្គនាយកដ្ឋាន<br>- សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ក្រុង |
| | ៧ | | | | - អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីរ ក្រសួង<br>- ប្រធានគណៈកម្មាធិការបក្សប្រជាជនបដិវត្តស្រុក<br>- ប្រធានមន្ទីរជុំវិញខេត្ត ក្រុង |
| | ៨ | | | | - អនុប្រធានប្រធានគណៈកម្មាធិការបក្សប្រជាជនបដិវត្តស្រុក<br>- អនុប្រធានមន្ទីរជុំវិញខេត្ត ក្រុង<br>- ប្រធានការិយាល័យនៃនាយកដ្ឋាន មន្ទីរក្រសួង និងអគ្គនាយកដ្ឋាន |
| | ៩ | | | | - សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការប្រជាជនបដិវត្តស្រុក<br>- អនុប្រធានការិយាល័យនៃនាយកដ្ឋាន មន្ទីរក្រសួង និងអគ្គនាយកដ្ឋាន<br>- ប្រធានការិយាល័យនៃមន្ទីរនានាជុំវិញខេត្ត ក្រុង |
| | ១០ | | | | - អនុប្រធានការិយាល័យនៃមន្ទីរនានាជុំវិញខេត្ត ក្រុង<br>- ប្រធានការិយាល័យស្រុក |
| | ១១ | | | | - អនុប្រធានការិយាល័យស្រុក |

# ទ.III : កម្មាភិបាលដឹកនាំផ្នែកអង្គការមហាជន - មាន ៧ ប្រភេទ

| តារាង | ប្រភេទ | កាំ | | ឋានៈ/តួនាទី |
|---|---|---|---|---|
| | | ១ | ២ | |
| ទ III | ១ | | | - ប្រធានរណសិរ្សមជ្ឈិម, សហជីព សមាគមយុវជនបដិវត្ត សមាគមនារីមជ្ឈិម |
| | ២ | | | - អនុប្រធានអចិន្ត្រៃយ៍ និងអគ្គលេខាធិការរណសិរ្សមជ្ឈិម<br>- អនុប្រធានអចិន្ត្រៃយ៍ សហជីព សមាគមយុវជនបដិវត្ត សមាគមនារីមជ្ឈិម |
| | ៣ | | | - អគ្គលេខាធិការរងរណសិរ្សមជ្ឈិម<br>- ប្រធាននាយកដ្ឋាន ប្រធានមន្ទីររណសិរ្ស សហជីព សមាគមយុវជន សមាគមនារីមជ្ឈិម |
| | ៤ | | | - អនុប្រធាននាយកដ្ឋាន អនុប្រធានមន្ទីររណសិរ្ស សហជីព សមាគមយុវជន សមាគមនារីមជ្ឈិម<br>- ប្រធានរណសិរ្ស សហជីព សមាគមយុវជន សមាគមនារីខេត្ត ក្រុង |
| | ៥ | | | - អនុប្រធានអចិន្ត្រៃយ៍រណសិរ្ស សហជីព សមាគមយុវជនបដិវត្ត សមាគមនារីខេត្ត ក្រុង |
| | ៦ | | | - ប្រធានសមាគមយុវជន សមាគមនារីស្រុក |
| | ៧ | | | -អនុប្រធានអចិន្ត្រៃយ៍ សមាគមយុវជន សមាគមនារីស្រុក |

# តារាង ខ : កម្មាភិបាល បុគ្គលិកបច្ចេកទេស និងរដ្ឋបាល - មាន ៤ ប្រភេទ

## ក្នុងមួយប្រភេទ មាន ៦ កាំ

| ប្រភេទ | | កាំប្រាក់ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| ខ | I | | | | | | | - សាស្ត្រាចារ្យកម្រិតសិក្សាទី៣ វិស្វករ បរិញ្ញាបត្រ ស្ថាបត្យករ<br>- មុខងារដែលមានសញ្ញាបត្រស្មើ |
| | II | | | | | | | - អ្នកបច្ចេកទេស សាស្ត្រាចារ្យកម្រិតសិក្សាទី២ គ្រូពេទ្យមធ្យម<br>- មុខងារដែលមានសញ្ញាបត្រស្មើ |
| | III | | | | | | | - ភ្នាក់ងារបច្ចេកទេស គ្រូកម្រិតសិក្សាទី១ BST គិលានុបដ្ឋាករដ្ឋ<br>- មុខងារដែលមានសញ្ញាបត្រស្មើ |
| | IV | | | | | | | - គ្រូកម្រិតសិក្សាទី១ តិចជាង ៧+១ គិលានុបដ្ឋាកជំនួយ<br>ឆ្មបបឋម |

# តារាង គ : កម្មករបច្ចេកទេស និងពលករសាធារណៈ - មាន ៤ ប្រភេទ

## ក្នុងមួយប្រភេទ មាន ៦ កាំ

| ប្រភេទ | | កាំប្រាក់ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| គ | I | | | | | | | - ជាងម៉ាស៊ីន ជាងអគ្គិសនី ជាងសំណង់ ជាងស្ពានថ្នល់<br>- អ្នកបើកបរត្រាក់ទ័រ រថយន្តដឹកជញ្ជូនធុនធ្ងន់ ជាងម៉ាស៊ីនអាស្សាណ្ឌ |
| | II | | | | | | | - កម្មករចៀរជ័រ កម្មករតម្បាញ កម្មករធ្វើកៅស៊ូកង់ឡាន ម៉ូតូ<br>- អ្នកបើកបររថយន្តធុនស្រាល |
| | III | | | | | | | - កម្មកររោងចក្រទឹកក្រូច ឧស្សាហកម្មស្បៀង អ្នកដាំបាយសណ្ឋាគារ<br>- ជាងដេរខោអាវ ................ |
| | IV | | | | | | | - ពលករសាធារណៈតាមក្រសួង មន្ទីរ រោងចក្រ សហគ្រាស<br>អ្នកបោសសំអាត អ្នកយាមទ្វារ................ |

● **តារាង គ :** បៀវត្សរ៍កម្មករបច្ចេកទេស និង ពលករសាធារណៈ មាន ៤ ប្រភេទ

ប្រភេទនីមួយៗមាន ០៦ កាំ

| ប្រភេទ | | កាំ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| គ | I | ២៣៤ | ២៥៤ | ២៧៩ | ៣០៤ | ៣២៩ | ៣៥៥ | - ជាងម៉ាស៊ីន, ជាងអគ្គិសនី, ជាងសំណង់, ជាងស្ពានថ្នល់<br>- អ្នកបើកបរត្រាក់ទ័រ, រថយន្តដឹកជញ្ជូនធុនធ្ងន់, ជាងម៉ាស៊ីនអាស្សាណូ |
| | II | ២១៣ | ២៣៤ | ២៦១ | ២៨៨ | ៣១៥ | ៣៤២ | - កម្មករចៀវជ័រ, កម្មករតម្បាញ, កម្មករធ្វើកៅស៊ូកង់ឡាន, ម៉ូតូ<br>- អ្នកបើកបររថយន្តធុនស្រាល.... |
| | III | ១៩២ | ២១០ | ២៣៤ | ២៥៨ | ២៨៣ | ៣០៨ | - កម្មកររោងចក្រទឹកក្រូច, ឧស្សាហកម្មស្បៀង, អ្នកដាំបាយសណ្ឋាគារ<br>- ជាងដេរខោអាវ..... |
| | IV | ១៤០ | ១៥៣ | ១៧០ | ១៨៧ | ២០៤ | ២២៤ | - ពលករសាធារណៈតាមក្រសួង មន្ទីរ រោងចក្រ សហគ្រាស, អ្នកបោស សំអាត, អ្នកយាមទ្វារ................ |

## ៣. ប្រព័ន្ធបៀវត្សបច្ចុប្បន្ន

ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១/១២/២០០១ ប្រព័ន្ធបៀវត្ស ត្រូវបានរៀបចំជា ៤ ប្រភេទៈ **ក ខ គ** និង **ឃ**

- ប្រភេទនីមួយៗ ចែកចេញជា ៣ ឋានន្តរសក្តិ៖

  - ឋានន្តរសក្តិទី១ មាន ៦ ថ្នាក់

  - ឋានន្តរសក្តិទី២ មាន ១០ថ្នាក់ និង

  - ឋានន្តរសក្តិទី៣ មាន ១៤ថ្នាក់

# ប្រព័ន្ធបៀវត្សបច្ចុប្បន្ន(ត)

សមាសភាគនៃបៀវត្សមន្ត្រីរាជការ៖

- បៀវត្សមូលដ្ឋាន
- ប្រាក់បន្ទាប់បន្សំនៃបៀវត្ស៖
  - ប្រាក់បំណាច់មុខងារ
  - ប្រាក់វិភាជន៍គ្រួសារ
  - ប្រាក់ឧបត្ថម្ភផ្សេងទៀត

ប្រាក់បៀវត្សមូលដ្ឋាន ត្រូវបានកំណត់ទៅតាមកម្រិតនៃសន្ទស្សន៍ ដូចមានក្នុងតារាងខាងក្រោម៖

# តារាងសន្ទស្សន៍បៀវត្សបច្ចុប្បន្ន

| | | 14 | 13 | 12 | 11 | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | 1 | | | | | | | | | 436 | 457 | 482 | 506 | 528 | 550 |
| | 2 | | | | | 361 | 373 | 387 | 402 | 419 | 437 | 454 | 467 | 478 | 487 |
| | 3 | 315 | 323 | 331 | 340 | 349 | 359 | 369 | 380 | 390 | 399 | 407 | 414 | 420 | 425 |
| ខ | 1 | | | | | | | | | 308 | 324 | 344 | 360 | 374 | 385 |
| | 2 | | | | | 252 | 262 | 272 | 283 | 295 | 306 | 316 | 325 | 333 | 340 |
| | 3 | 220 | 225 | 230 | 236 | 243 | 251 | 259 | 266 | 273 | 279 | 284 | 289 | 293 | 297 |
| គ | 1 | | | | | | | | | 212 | 223 | 235 | 245 | 254 | 262 |
| | 2 | | | | | 173 | 178 | 185 | 193 | 201 | 208 | 215 | 222 | 228 | 233 |
| | 3 | 150 | 154 | 158 | 163 | 168 | 174 | 179 | 184 | 188 | 192 | 195 | 198 | 200 | 202 |
| ឃ | 1 | | | | | | | | | 141 | 149 | 157 | 164 | 170 | 175 |
| | 2 | | | | | 113 | 117 | 122 | 128 | 134 | 139 | 144 | 148 | 152 | 155 |
| | 3 | 100 | 102 | 104 | 106 | 109 | 112 | 116 | 120 | 123 | 126 | 129 | 131 | 133 | 135 |

# តារាងសន្ទស្សន៍បៀវត្សបច្ចុប្បន្ន

| | | 14 | 13 | 12 | 11 | 10 | 9 | 8 | 7 | 6 | 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក | 1 | | | | | | | | | 436 | 457 | 482 | 506 | 528 | 550 |
| | 2 | | | | | 361 | 373 | 387 | 402 | 419 | 437 | 454 | 467 | 478 | 487 |
| | 3 | 315 | 323 | 331 | 340 | 349 | 359 | 369 | 380 | 390 | 399 | 407 | 414 | 420 | 425 |
| ខ | 1 | | | | | | | | | 308 | 324 | 344 | 360 | 374 | 385 |
| | 2 | | | | | 252 | 262 | 272 | 283 | 295 | 306 | 316 | 325 | 333 | 340 |
| | 3 | 220 | 225 | 230 | 236 | 243 | 251 | 259 | 266 | 273 | 279 | 284 | 289 | 293 | 297 |
| គ | 1 | | | | | | | | | 212 | 223 | 235 | 245 | 254 | 262 |
| | 2 | | | | | 173 | 178 | 185 | 193 | 201 | 208 | 215 | 222 | 228 | 233 |
| | 3 | 150 | 154 | 158 | 163 | 168 | 174 | 179 | 184 | 188 | 192 | 195 | 198 | 200 | 202 |
| ឃ | 1 | **145** | **149** | **153** | **158** | **163** | **169** | **174** | **179** | **183** | **187** | **190** | **193** | **195** | **197** |

# ការកែសម្រួលបាននូវស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងាររបស់ក្របខ័ណ្ឌនាក់ងាររដ្ឋបាល នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងនាក់ងារបច្ចេកទេស

ផ្អែកលើព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១២០ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

តារាងសន្ទស្សន៍ថ្មីនៃក្របខ័ណ្ឌប្រភេទ ឃ ត្រូវបានកំណត់ ដូចខាងក្រោម៖

| ប្រភេទ ឃ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| សន្ទស្សន៍ | ១៤៥ | ១៤៩ | ១៥៣ | ១៥៨ | ១៦៣ | ១៦៩ | ១៧៤ | ១៧៩ | ១៨៣ | ១៨៧ | ១៩០ | ១៩៣ | ១៩៥ | ១៩៧ |

**ថ្នាក់ និង ឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌថ្នាក់ខាររដ្ឋបាល ថ្នាក់ខាររដ្ឋបាល ក្រសួងមហាផ្ទៃ និងថ្នាក់ខារបច្ចេកទេស ត្រូវបានកែសម្រួលទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលប្រភេទ ឃ ថ្មី ដូចខាងក្រោម៖**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| – | ឃ.៣.១៤ | និង | ឃ.៣.១៣ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១៤ | ថ្មី |
| – | ឃ.៣.១២ | និង | ឃ.៣.១១ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១៣ | ថ្មី |
| – | ឃ.៣.១០ | និង | ឃ.៣.៩ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១២ | ថ្មី |
| – | ឃ.៣.៨ | និង | ឃ.៣.៧ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១១ | ថ្មី |
| – | ឃ.៣.៦ | និង | ឃ.៣.៥ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១០ | ថ្មី |
| – | ឃ.៣.៤ | និង | ឃ.៣.៣ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៩ | ថ្មី |
| – | ឃ.៣.២ | និង | ឃ.៣.១ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៨ | ថ្មី |
| – | ឃ.២.១០ | និង | ឃ.២.៩ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៧ | ថ្មី |
| – | ឃ.២.៨ | និង | ឃ.២.៧ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៦ | ថ្មី |
| – | ឃ.២.៦ | និង | ឃ.២.៥ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៥ | ថ្មី |
| – | ឃ.២.៤ | និង | ឃ.២.៣ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៤ | ថ្មី |
| – | ឃ.២.២ | និង | ឃ.២.១ | ចាស់ | | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.៣ | ថ្មី |
| – | ឃ.១.៦ | ឃ.១.៥ | និង | ឃ.១.៤ | ចាស់ | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.២ | ថ្មី |
| – | ឃ.១.៣ | ឃ.១.២ | និង | ឃ.១.១ | ចាស់ | ត្រូវបានធ្វើសមាហរណកម្មចូលក្នុង | ឃ.១ | ថ្មី |

ជម្រើសរបស់យើង៖

- ការធ្វើកំណែទម្រង់ គឺជាកត្តាចាំបាច់
- បញ្ហាសំខាន់ គឺ ការគ្រប់គ្រងការផ្លាស់ប្តូរ